៣- បើការជម្លៀសប្រជាជនពីទីក្រុង វាហាក់ដូចជាវិធានការណ៍មួយដែលតម្រូវទៅតាមសភាពការណ៍នៅពេលនោះដោយជៀសមិនផុត ការមិនចាយលុយ ការពង្រីក “សហករណ៍កម្រិតខ្ពស់” ទូទាំងប្រទេស ការគ្រប់គ្រងប្រទេសដោយវិន័យតឹងរឹងដូចកាលនៅក្នុងសង្គ្រាមនោះ ពិតជាមកពីមនោគមវិជ្ជាជ្រុលហួសរបស់លោកប៉ុលពតហើយ។

“សហករណ៍កម្រិតខ្ពស់” ត្រូវបានចាត់តាំងឡើងក្នុងឆ្នាំ១៩៧៣ គឺនៅពេលដែលសង្គមនៅជនបទ កម្ពុជាត្រូវបានខ្ទាត់ខ្ទាយខ្ទេចខ្ទីដោយការទម្លាក់គ្រាប់បែកបេ៥២ក្រាលព្រំ។ ដីត្រូវបានប្រកាសទៅជាដីរបស់សហករណ៍។ ផលប្រចាំឆ្នាំ ក៏ត្រូវបានប្រកាសជាកម្មសិទ្ធិរួមរបស់សហករណ៍ លែងត្រូវបានចែកតាមផ្ទះដូចមុនទៀតហើយ។ ម្នាក់ៗត្រូវបើកអង្ករតាមរបបដែលគេកំណត់ឲ្យ។ នៅក្នុងសភាពការណ៍ដែលប្រទេសបានត្រូវខ្ទេចខ្ទាំខ្ទាំងដោយសង្គ្រាមហើយ ស្រែមួយផ្នែកធំត្រូវបោះបង់ចោលធ្វើលែងបាន មានតែធ្វើដូច្នេះទេ ទើបចែកគ្នារស់បាន ហើយមានសល់ស្រូវចិញ្ចឹមកងទ័ព ដើម្បីប្រយុទ្ធយកឈ្នះសង្គ្រាមបាន។ ទោះបីយ៉ាងនេះ ក៏នៅគង់តែមានចលនាប្រឆាំង។ នៅរយៈពេលដំបូងចលនានេះមានរូបភាពជាការកាប់ គោ ក្របី យកសាច់ចែកគ្នាហូប ដើម្បីជៀសវាងមិនយកទៅដាក់រួមនៅក្នុងសហករណ៍។ តៗមកទៀតក៏មានរូបភាពជាការលួចស្រូវ អង្ករពីជង្រុករួមយកទៅបង្កើនរបបរបស់ខ្លួននិងគ្រួសារនៅតាមផ្ទះ។ ប៉ុន្តែដោយប្រៀបធៀបមហាជនជាទូទៅនៅស៊ូទ្រាំទទួលយកសហករណ៍កម្រិតខ្ពស់នេះ ធ្វើម៉េចឲ្យតែរំដោះប្រទេសបាន ហើយបានសន្តិភាពមកវិញ។ ប៉ុន្តែដល់ចប់សង្គ្រាមហើយ ប្រជាជនជាទូទៅមិនឃើញហេតុផលអ្វី ដើម្បីរក្សាការចាត់តាំងដ៏តឹងរឹងនេះទៀតទេ។ បើប្រសិនជាត្រឡប់មកយករូបភាពសហករណ៍ ដែលបានចាត់តាំងនៅឆ្នាំ១៩៧១-១៩៧២ ដោយមានការចែកចាយផលប្រចាំឆ្នាំដោយយោងទៅតាមទំហំដីរបស់ម្នាក់ៗនៅក្នុងសហករណ៍ ប្រហែលជាសមស្របទៅនឹងសំណូមពររបស់ប្រជាជនជាង។ ឯការចែកផលទៅតាមទំហំដីរបស់សមាជិកម្នាក់ៗ ក៏មិនខុសគ្នាប៉ុន្មានទេ ព្រោះទំហំដីរបស់ម្នាក់ៗប្រហាក់ប្រហែលគ្នាទេ ក្រោយពីមាន



ការដឹកនាំឲ្យអ្នកដែលមានដីច្រើន ចែករំលែកដីឲ្យកសិករដែលខ្វះដី កាលពីឆ្នាំ១៩៧០-១៩៧១។ បើមានការចាយលុយ ក៏ជាការបើកសិទ្ធិឲ្យម្នាក់ៗ ពិសេសបងប្អូនជម្លៀសដែលគេមានមាស ឬគ្រឿងអលង្ការជាប់នឹងខ្លួនយកទៅទិញដូររបស់របរផ្សេងៗ ដែលគេត្រូវការចាំបាច់។ ព្រមជាមួយនេះ ការប្រើបញ្ញាជនដែលបានខិតខំធ្វើការ និងបង្ហាញថាគេទទួលធ្វើតាមមាគ៌ារបស់បក្សទៅតាមមុខជំនាញរបស់គេម្នាក់ៗ នោះក៏ការបង្ហាញឲ្យទាំងអស់គ្នាឃើញថា រដ្ឋអំណាចថ្មីមិនមានទិសដៅអ្វីទៅកំចាត់គេទេ ផ្ទុយទៅវិញ គឺចង់កសាងគេតាមគន្លងនៃប្រពៃណីជាតិ ស្អាតស្អំ និងត្រឹមត្រូវរបស់កសិករយើង។

លោកហ្វីលីព ហ្សូត បានមើលឃើញ ត្រូវនៅពេលដែលគាត់សរសេរថា៖ “ប៉ុលពតមិនមានបំណងអ្វីចង់បន្ថយចំនួនប្រជាជនទេ តែផ្ទុយទៅវិញគាត់មានទិសដៅ បង្កើនចំនួនប្រជាជនទ្វេរជាពីរ ឬ បីដង។ ជាក់ស្តែងគាត់ចង់ឲ្យប្រជាជនកម្ពុជាកើនទៅដល់ “១៥ ឬ២០លាននាក់ក្នុងរយៈ១០ឆ្នាំខាងមុខនេះ” គឺជាចំនួនដែលចាំបាច់ ដើម្បីសម្រេចគំរោងផ្សេងៗដែលនឹងនាំមកនូវកម្លាំង និង ភាពរុងរឿងដល់ប្រទេស។ តែធ្វើម្តេចនឹងសម្រេចទិសដៅនេះបាន បើនារីរាំងរដូវដោយសារតែការអត់ឃ្លាននោះ? ក្រុមដឹកនាំឃើញបញ្ហានេះ។ សេចក្តីសម្រេចចិត្តរបស់គណៈអចិន្ត្រៃយ៍នៅពេលនោះ សន្ទរកថារបស់លោកប៉ុលពតនៅក្នុងអង្គប្រជុំចង្អៀតរបស់បក្ស តែងនិយាយជាច្រើនលើកច្រើនសារ អំពីការចាំបាច់ដោះស្រាយឲ្យមានរបបហូបសមរម្យ គឺស្រូវ៥០០ក្រាម សម្រាប់ម្នាក់ៗក្នុងមួយថ្ងៃជាមធ្យម”។ “នៅក្នុងសន្និសីទមួយ ដែលគាត់ធ្វើនៅភាគខាងលិច គាត់បានសង្កត់ថា ថ្នាំដែលសំខាន់ជាងគេ គឺម្ហូបអាហារ។ ដោះស្រាយបញ្ហាហូបចុកនេះជាគន្លឹះ”។ ពីរខែក្រោយមក គាត់ក៏និយាយពីរឿងនេះទៀត ៖

“យើងត្រូវតែដោះស្រាយជីវភាពប្រជាជន ហើយដោះស្រាយឲ្យឆាប់... (បើមិនដូច្នេះទេ) នឹងមានទំនាស់រវាងគ្នាយើងហើយ” [២០១]។ អ្នកនិពន្ធបាន

[២០១] ហ្វីលីព ហ្សូត “ប៉ុល ពត...” ទំព័រ៣២១

និយាយអំពីកំណត់ហេតុដូចតទៅ "របបអង្ករត្រូវតែបានពីរកំប៉ុងក្នុងមួយថ្ងៃ បើមិនបានប៉ុណ្ណោះទេ សុខភាពរបស់មនុស្ស និង កម្លាំងការងារត្រូវថយចុះ"[២០២]។ អ្នកនិពន្ធក៏បានកត់សម្គាល់ថា ដោយឯកសារទាំងនោះ ជាពិសេសកំណត់ហេតុនៃគណៈអចិន្ត្រៃយ៍ ដែលមានផ្សាយតែក្នុងចំណោមមនុស្សតិចជាង១០ នាក់ ដូច្នេះសម្ងាត់បំផុត មិនមែនសម្រាប់ផ្សាយទូលាយទេ គេអាចជឿបានថាគំនិតដែលប៉ុលពតបានលើកឡើងនៅក្នុងឯកសារទាំងនោះ គឺស្មោះត្រង់។

ប៉ុន្តែលោកហ្វីលីព ហ្សុតយល់ឃើញថា ទំនាស់វាស្ថិតក្នុងនយោបាយរបស់លោកប៉ុលពតតែម្តង "នៅពេលដែលមានការខ្វះខាតជាទូទៅ លោកណែនាំឲ្យកម្មាភិបាល រៀបចំរបបហូបយ៉ាងហោចណាស់ឲ្យបានសមរម្យទាំងអស់គ្នា ប៉ុន្តែលោកនៅរក្សាឲ្យមានរបបខុសគ្នា សម្រាប់ "ប្រជជនថ្មី" និង "ប្រជាជនចាស់"។

និយាយម្យ៉ាងទៀត គឺត្រូវជានាឲ្យអ្នកទទួលខុសត្រូវដែលរស់នៅដាច់ពីមហាជន... និងក្រុមដែលមាន "សិទ្ធពិសេសេ" មួយចំនួនមានការហូបចុកហូសពីពម្មតាផង... ហើយរក្សាភាពអត់ឃ្លាន សម្រាប់ជាវិន័យផង...។[២០៣] ប៉ុន្តែផ្ទាល់ខ្លួនខ្ញុំ ខ្ញុំមិនដែលឃើញមានការណែនាំឲ្យមានការបែង ចែករបបខុសគ្នារវាងប្រជាជនថ្មី និងប្រជាជនចាស់ទាល់តែសោះ។ បើប្រសិនជាមានការណែនាំរបៀបនេះមែន វាត្រូវតែយកមកជជែកវែកញែកនៅក្នុងគណៈមជ្ឈិមហើយ។ និយាយយ៉ាងនេះ ខ្ញុំមិនបដិសេធថា គ្មាន "កម្មាភិបាលទទួលខុសត្រូវដែលរស់នៅដាច់ពីមហាជន ហើយគ្មានក្រុមដែលមាន "សិទ្ធិពិសេស" នោះទេ។ ប្រធានភូមិភាគទាំង៦ជាស្តេចត្រាញ់ទៅហើយ ការដែលមានកម្មាភិបាល ឬក្រុមដែលមានសិទ្ធិពិសេសនោះ មិនមែនជាការចំឡែកអ្វីទេ។ ប៉ុន្តែខ្ញុំយល់ឃើញថា ត្រូវតែរៀបចំឲ្យមាន "របបហូបចុកឲ្យសមរម្យ" សម្រាប់កងទ័ពជាដើម។ មិនមែនដោយហេតុផលថាការស្មោះត្រង់របស់គេ ចំពោះ

[២០២] កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ប.ក.ក ១៩៧៦

[២០៣] ហ្វីលីព ហ្សុត "ប៉ុល ពត..." ទំព័រ៣២១



របបនោះ ជាសំខាន់ទេ ប៉ុន្តែដើម្បីឲ្យកងទ័ពអាចបំពេញភារកិច្ចការពារប្រទេសបាន។ ចំណែកឯអង្គភាពខ្លះ ដូចលោក ហ្វីលីព ហ្សុត បានលើកពីអង្គភាពរទេះភ្លើង ឬអង្គភាពដែលធ្វើការតាមរោងចក្រនៅភ្នំពេញ (ឬក៏អង្គភាពជាច្រើនផ្សេងទៀតដែលធ្វើការនៅតាមមាត់ទន្លេ) ក៏អាចមានពេលខ្លះ សំបូរហូរហៀរ ជាពិសេសនៅក្នុងខែ វិច្ឆកា និង ធ្នូរ ដែលសំបូរត្រី។

៤- ចុះហេតុម្តេចបានជាមានការបែងចែករវាង "ប្រជាជនថ្មី" និង "ប្រជាជនចាស"?

តាំងពីដើមរៀងមក បក្ស កងទ័ព និង រដ្ឋអំណាចតាមថ្នាក់ផ្សេងៗ គឺឈរលើមូលដ្ឋានវណ្ណៈ ហើយត្រូវចេញមកពី "ចលនាមហាជន"។ មានន័យថា ទាំងអស់គ្នាត្រូវបង្ហាញនូវការប្តូរ ប្តេជ្ញា ប្រយុទ្ធ ដើម្បីការពារបក្ស ការពារកងទ័ព និង ការពាររដ្ឋអំណាច។ ការអនុវត្តគោលការណ៍នេះ អាចមានការបន្ធូរបន្ថយបន្តិចនៅក្នុងក្របខណ្ឌរដ្ឋអំណាចខាងក្រោម ប៉ុន្តែគេមិនដែលបោះបង់ចោលគោលការណ៍នេះសោះទេ។ ដោយប្រជាជានជម្លៀសមិនដែលទាំងស្គាល់បក្ស កងទ័ព និង រដ្ឋអំណាចបដិវត្តន៍ផងនោះ គេពុំអាចមានលទ្ធភាពចូលធ្វើការនៅក្នុងរដ្ឋអំណាច សូម្បីតែថ្នាក់ទាប ដូចជាថ្នាក់ភូមិ ឬសហករណ៍ ឬធ្វើជាយុទ្ធជន កងទ័ពបាននៅឡើយទេ។ នេះគឺជាគោលការណ៍ប្រុងប្រយ័ត្នកុំឲ្យភ្នាក់ងាររបស់ប្រទេសខ្លះ អាចចូលមកស៊ីរូងរដ្ឋអំណាចបដិវត្តន៍កម្ពុជាបាន។ ដូច្នេះត្រូវតែក្តាប់ប្រវត្តិរូបរបស់ម្នាក់ៗ។ ហើយដើម្បីកម្មាភិបាល កសិករ ងាយក្តាប់ប្រវត្តិរូបម្នាក់ៗ វិធីដែលងាយបំផុត គឺការបែងចែកជាប្រជាជនចាស់ ប្រជាជនថ្មី ។

ប៉ុន្តែ "ប៉ុលពតខ្លួនឯង តែងក្រើនរំលឹកកម្មាភិបាលទាំងអស់ឲ្យខិតខំជៀសវាងកុំចាត់ទុកប្រជាជនថ្មីទាំងអស់ជាសត្រូវ (ឬជាឈ្លើយសឹក) ដោយមិនគិតគូដល់គោលជំហរ គោលការណ៍ និងទស្សនៈរបស់បក្ស"[២០៤]។ ប៉ុន្តែ

[២០៤] ហ្វីលីព ហ្សុត "ប៉ុល ពត..." ទំព័រ២៩៦ (អ្នកនិពន្ធយោងទៅឯកសារ "ប៉ុល ពត ៖ សេចក្តីរាយការណ៍" ទំព័រ២០៧)

ក្នុងការជាក់ស្ដែង នៅជាច្រើនកន្លែង "ប្រជាជនថ្មី" នៅតែត្រូវគេចាត់ទុកថា ជាឈ្លើយសឹក ដូចកាលពីគេត្រូវជម្លៀស កាលពីថ្ងៃដំបូងម្ល៉េះ។ ដូច្នេះហើយ បានជាបង ប្អូនជម្លៀសភាគច្រើនយល់ថា របបនេះមានចេតនាសម្លាប់គេឲ្យ អស់ ទុកតែ "ប្រជាជនចាស់" ជាវណ្ណៈតែមួយដែលនៅសល់ក្នុងប្រទេស។ ប៉ុន្តែការពិត ខ្មែរក្រហមមិនដែលមានចេតនាយ៉ាងនេះទាល់តែសោះ។ ព្រឹត្តិការណ៍ដែលកើតមាននៅរយៈ៣ឆ្នាំនៃកម្ពុជាប្រជាធិបតេយ្យ គឺមកពី "ការទាក់ទងខាងផ្លូវរដ្ឋអំណាច រវាងពួកខ្មែរក្រហមនៅតែបន្តប្រព្រឹត្តទៅ តាមខ្សែ ដែលនៅក្នុងនោះ លេខាភូមិភាគដែលជានាម៉ឺនជំនាន់ថ្មី មាន នាទីជាស្ដេចត្រាញ់នៅតាមខេត្ត ស្មោះត្រង់ចំពោះដឹកនាំកណ្ដាលនៃប.ក.ក. ប៉ុន្តែនៅមានអំណាចផ្ទាល់ខ្លួនធំទូលាយនៅឡើយ ដើម្បីគេធ្វើតាមតែការ យល់ឃើញរបស់គេ"។[២០៥] សូមរំលឹកអំពីវៀតណាម ប្រើកងរបស់លោក ចាន់ ចក្រី ឲ្យក្លែងខ្លួនធ្វើជាកងទ័ព "ខ្មែររំដោះ" នោះទៅ នោះយើងអាច យល់បានហើយថាតើពាក្យថា "នៅមានអំណាចផ្ទាល់ខ្លួនធំទូលាយនៅ ឡើយ ដើម្បីគេធ្វើតាមតែការយល់ឃើញរបស់គេ" នោះ វាទូលំទូលាយ កម្រិតណា។

៤- ចុះហេតុម្ដេចបានជាបង្ខំគេឲ្យធ្វើការហួសកម្លាំង តាមពាក្យស្លោក ថា "វ៉ៃសំរុក វ៉ៃសំរុក" ដើម្បីធ្វើ "បដិវត្តន៍សង្គមនិយម និងកសាងសង្គម និយម"?

គឺមកពីលោកប៉ុលពត ឃើញថា ត្រូវ "រត់ឲ្យលឿន រត់ឲ្យលឿន" ដើម្បី ដោះស្រាយ "វិបត្តិម្ហូបអាហារ និង កសិកម្ម" ដែលលោកហ្សូវក្រួស និង សេចក្ដី រាយការណ៍នៃផ្នែកដែលគិតគូរពីជំនួយបរទេស បាននិយាយហើយដែល យើងបានដកស្រង់ជូនពីខាងលើ។ ហើយដើម្បីរត់ឲ្យលឿន លោកប៉ុលពត យល់ឃើញថា ការចាត់តាំងឲ្យមានសហករណ៍កម្រិតខ្ពស់នៅទូទាំងប្រទេស

[២០៥] ហ្វីលីព ហ្សូត "ប៉ុល ពត..." ទំព័រ៣២០



នឹងធ្វើឲ្យបដិវត្តន៍នៅកម្ពុជាបានឈានទៅមុខ "៣០ឆ្នាំ លឿនជាងបដិវត្តន៍ ចិន កូរ៉េ (ខាងជើង) និង វៀតណាម" ពីព្រោះវាបើកលទ្ធភាពយ៉ាងធំទូលាយ ដើម្បីធ្វើទំនប់ ជីកប្រឡាយ ស្រោចស្រពជនបទទូទាំងប្រទេស ហើយបើក ទស្សនៈធំទូលាយ ដើម្បីកសិកម្មកម្ពុជាចេញរួចផុតពីកសិកម្មអន់ថយ ទៅ ជាកសិកម្មទំនើប។ ដូច្នេះប្រទេសយើងនឹងបានជាមូលដ្ឋានមួយរឹងមាំ ដើម្បី កែប្រែជីវភាពប្រជាជនកម្ពុជាជាលំដាប់លំដោយផង ហើយកម្ពុជាប្រែក្លាយ ទៅជាប្រទេសឧស្សាហកម្មជាជំហានៗផង។ គឺក្នុងស្មារតីនេះហើយ ដែល លោកប៉ុលពតជំរាបសហការីរបស់លោកថា: "ជាបណ្ដើរៗទៅមហាជននឹង ខិតមកកាន់តែជិតជាមួយបក្សវិញ"។[២០៦] លោកហ្វីលីពហ្សូត ទទួលស្គាល់ថា ការដែលលោកប៉ុពតមានប្រសាសន៍យ៉ាងនេះ មិនមែនជាការឃោសនាទេ។ "ប៉ុលពតជឿដោយស្មោះថា គាត់បានខិតខំដើម្បីផលប្រយោជន៍ទាំងអស់គ្នា ហើយគិតថា មិនយូរមិនឆាប់ទាំងអស់គ្នានឹងយល់។ ការដែលចង់បានអំណាច គឺការចង់ត្រួតត្រាលើជីវភាពគ្រប់បែបយ៉ាងរបស់ប្រជាជន ដើម្បីសំដៅឈាន ទៅសម្រេចទិសដៅមួយដ៏ធំធេង ដែលលោកតែម្នាក់ឯងជាអ្នកកាន់កូនសោរ នោះច្បាស់ជាមានហើយ។ ប៉ុន្តែទិសដៅមិនមែនបង្ខំប្រជាជនទេ គឺពន្យល់ ប្រជាជនឲ្យយល់ "នូវការចាំបាច់ថាត្រូវតែខិតខំធ្វើការងារ"។ ប៉ុន្តែជនរួមជាតិ របស់គាត់មិនយល់គាត់"។[២០៧] តាមយោបល់ខ្ញុំ ភារកិច្ចដែលត្រូវពន្យល់អំពី ការចាំបាច់ត្រូវខិតខំធ្វើការ គ្មានអ្នកណាក្រៅពីប្រធានភូមិភាគទាំង៦នោះទេ ពីព្រោះគេនៅនឹងកន្លែងផ្ទាល់តែម្ដង។ ប៉ុន្តែតាមធាតុរបស់គេជាស្ដេចត្រាញ់ គេមិនជាប់ជាមួយប្រជាជនទេ គេមិនអាចខិតខំពន្យល់ប្រជាជន ពិសេស បងប្អូនជម្លៀសដោយអំណត់ ព្យាយាម យល់ដឹងទុក្ខធុរៈ បងប្អូន ជម្លៀស ផងនោះទេ គេមានតែស្ដីបន្ទោសចោទប្រកាន់ និង គំរាមកំហែងតែប៉ណ្ណោះ។

[២០៦] ហ្វីលីព ហ្សូត "ប៉ុល ពត..." ទំព័រ២៩២

[២០៧] ហ្វីលីព ហ្សូត "ប៉ុល ពត..." ទំព័រ២៩២ (អ្នកនិពន្ធយោងទៅឯកសារ "ប៉ុល ពត ៖ សេចក្ដីរាយការណ៍" ទំព័រ២០៧)

ម្យ៉ាងទៀត ការលំបាករបស់បក្សកុម្មុនិស្តកម្ពុជាក្នុងការទាក់ទងជាមួយបក្សពលករវៀតណាម តាំងពីបក្សកុម្មុនិស្តកម្ពុជាកកើតថ្ងៃណាមក ហើយជាពិសេសការដែលបក្សពលករវៀតណាម បានលូកដៃយ៉ាងជ្រៅចូលមកកក្កូរផ្ទៃក្នុងបក្ស និង ផ្ទៃក្នុងកងទ័ពតស៊ូកម្ពុជា បានធ្វើឲ្យលោក ប៉ុលពត មានជំនឿជឿជាក់ថា កម្ពុជាចាំបាច់រៀបចំខ្លួនដើម្បីប្រឈមមុខទល់នឹងការគំរាមកំហែងពីហាណូយថ្ងៃណាមួយ ដោយជៀសមិនផុតទេ។ ដូចគាត់បានថ្លែងនៅចំពោះមុខគណៈអចិន្ត្រៃយ៍ៈ "យើងត្រូវខំរត់ឲ្យលឿនដើម្បីកុំឲ្យវៀតណាមដេញទាន់"។[២០៨]

៦- ទោះបីជាយ៉ាងណាក៏ដោយ ការខិតខំរត់ហើយរត់ទៀតឥតឈប់ឈរ ក្នុងការធ្វើ "បដិវត្តន៍សង្គមនិយម និង កសាងសង្គមនិយម" បានប្រព្រឹត្តទៅក្នុងសភាសពការណ៍ដែលច្របូកច្របល់ខ្លាំងណាស់ ក្នុងនេះ ការបង្អត់បាយប្រជាជនដោយថា ដើម្បីដឹកស្រូវទៅជូនរដ្ឋឲ្យគ្រប់តាមការកំណត់បាននាំឲ្យមានការបាត់បង់ជីវិតមនុស្សអស់ច្រើនណាស់។ ក្នុងនេះ បញ្ហាដែលចោទសួរទៀត គឺថា តើការដែលវៀតណាមលូកដៃយ៉ាងជ្រៅចូលមកកក្កូរផ្ទៃក្នុងប.ក.ក. ដែលបានលេចឡើងយ៉ាងច្បាស់ក្រឡែតកាលពីឆ្នាំ១៩៧៣ អាចចប់ឬនៅ នៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៨នោះ? ទោះបីយ៉ាងណាក៏ដោយ ការច្របូកច្របល់នៅពេលនោះ ក៏ជាកត្តាមួយសំខាន់ នាំឲ្យកម្មាភិបាលល្អៗជាច្រើនដែលកន្ទ្រងមកស្មោះត្រង់ចំពោះបុព្វហេតុ ហើយសកម្មប្រយុទ្ធបែរទៅជាភពយ។ ការស្មាក់ស្មើររបស់គេចំពោះមុខសភាពការណ៍នេះ ក៏គួរឲ្យយើងយល់បានដែរ។ ប៉ុន្តែស្ថិតនៅចំពោះមុខការប៉ុនប៉ងជាច្រើនលើកច្រើនសាររបស់មេដឹកនាំកុម្មុយនីស្តវៀតណាម ហើយឱសានវាទរបស់វៀតណាមនៅខែឧសភា ឆ្នាំ១៩៧៦ ដាក់មកលើកម្ពុជា បានជំរុញឲ្យលោកប៉ុលពត និងក្រុមដឹកនាំ ប.ក.ក ឈានមកដល់សេចក្តីសន្និដ្ឋានថា "ការកំទេចរនុកក្នុងរបស់វៀតណាមជាផ្លូវតែមួយគត់ដើម្បីកម្ពុជារស់"។

[២០៨] ហ្វីលីព ហ្សុត "ប៉ុល ពត..." ទំព័រ២៩២



និយាយមួយម៉ាត់ បញ្ហាវាស្មុគស្មាញ មហាស្មុគស្មាញ។ គេមិនអាចសន្និដ្ឋានបានតាមពាក្យមួយម៉ាត់ពីរម៉ាត់បានទេ។

ក្រោយឆ្នាំ១៩៧៩ អ្នកដឹកនាំខ្មែរក្រហមតែងនិយាយអំពីពួកកម្មាភិបាលដែលចេញមកពី "សង្គ្រាម៩ឆ្នាំ" បានអនុវត្តន៍នយោបាយ "ដុតឲ្យខ្មោចរោចឲ្យឆៅ" ទាំងក្នុងការចាប់ចងនិងសម្លាប់មនុស្ស ដូចយើងបានឃើញក្នុងរឿងសមមិត្តវី សមមិត្តឡៅបំភ្លៃមាគ៌ា ទាំងក្នុងការបង្អត់បាយប្រជាជនដើម្បីធ្វើឲ្យប្រជាជនស្អប់ និងមានកំហឹងចំពោះកម្ពុជាប្រជាធិបតេយ្យ ឯកោកម្ពុជាប្រជាធិបតេយ្យ ពីជាតិ និងប្រជាជនដើម្បីវៀតណាមងាយចូលមកឈ្លានពាន។ បញ្ហានេះក៏គួរស្រាវជ្រាវ ហើយស្រាវជ្រាវដោយទី១ ភ្ជាប់ទៅនឹងការដែលគេបង្អត់បាយប្រជាជនដើម្បីថា ដឹកស្រូវជូនរដ្ឋ ចំណែកឯរដ្ឋក៏នៅតែមិនមានស្រូវ ដើម្បីនាំចេញទៅលក់នៅឯបរទេសផង ទី២ភ្ជាប់ទៅនឹងសភាពការណ៍ ដែលលោកហ្វីលិព ហ្សុតបានសរសេរអំពីប្រធានភូមិភាគទាំងប្រាំមួយ ព្រមទាំងការទាក់ទងពីមេទៅកូនតាមបែបរបបសក្តិភូមិ ដែលវាចាក់ឫសជ្រៅនៅក្នុងសង្គមកម្ពុជាផង ។

**ទី៨- ហេតុអ្វីបានជាលោកប៉ុលពតជឿតាម៉ុកខ្លាំងម្ល៉េះ?**

ប្រហែលជាមកពី ៖

ក- ចលនាមិនមានពេលប្រមូលកម្លាំងប្រដាប់អាវុធមករៀបចំ ជាកងទ័ពឯកភាពតែមួយសម្រាប់ទូទាំងប្រទេស។ កងទ័ពស្ថិតក្នុងដៃភូមិភាគ និងតំបន់ៗ រដ្ឋអំណាចកណ្តាលមិនមានកងទ័ពនៅនឹងដៃខ្លួនឯងទេ។ ការពិតក្នុងរយៈពេលតែ៥ឆ្នាំនៃសង្គ្រាមជាការលំបាក និងសម្រេចការងារនេះណាស់។ ដូច្នេះប៉ុលពតត្រូវតែទៅពឹងលើតាម៉ុក នៅគ្រប់ពេលដែលគាត់ជួបប្រទះនឹងការប្រឆាំង ឬនៅពេលដែលគាត់ឃើញមានការរវាតពីមាគ៌ារួម ហើយមិនព្រមកែតម្រង់វិញ។

ខ- ម្យ៉ាងទៀតដូចយើងបានឃើញពីលើមកហើយ គឺមកពីតាម៉ុកបានលេចឡើងចំពោះមុខប៉ុលពតជាអ្នកដឹកនាំមួយរូប ដែលចេញមកពីកសិករ។

គាត់ខុសពីកម្មាភិបាលផ្សេងទៀតដែលចេញមកពីសង្គ្រាម៩ឆ្នាំ។ គាត់មិនផឹកស្រាទេ។ គាត់គ្មានស្រីទេ។ គាត់រស់នៅសាមញ្ញបំផុត។ គាត់ប្រកាន់ជំហរឯករាជ្យច្បាស់លាស់ មិនពឹងលើកម្លាំងវៀតណាមដែលបោះនៅកម្ពុជាពេលនោះទេ។ គាត់មានថ្វៃអាវុធច្រើន តាំងពីថ្ងៃដំបូងនៃការផ្ទុះអាវុធកាលពីឆ្នាំ ១៩៦៨-៦៩ ហើយជាបន្តបន្ទាប់ក្នុងសង្គ្រាមពីឆ្នាំ១៩៧០ ដល់ ១៩៧៥។ ពិតមែនហើយក្នុងខ្លួនគាត់មានអ្វីដែលគួរឲ្យគោរពផង គួរឲ្យខ្លាចញញើតផង។ គាត់ជានិមិត្តរូបនៃស្មារតីស្នេហាជាតិដ៏ខ្ពង់ខ្ពស់ផង ជាអ្នកកាចតាមរបៀបពួកឥស្សរៈផង។ ឧទាហរណ៍ដូចជា ជាមួយសូ ភឹម និងកម្មាភិបាលបូព៌ាជាដើម។ គាត់ដឹងតែពីស្អប់មិនពេញចិត្ត។ គាត់មិនយល់អំពីមាគ៌ាប្រមូលកម្លាំងធំទូលាយ ដើម្បីវាយឲ្យចំខ្មាំងសត្រូវដែលវាឃោរឃៅជាងគេនោះទេ។ គាត់មិនយល់គោលការណ៍វិភាគអំពីឯកភាព និងទំនាស់ និងមាគ៌ាតស៊ូសាមគ្គីសាមគ្គីតស៊ូនោះទេ។ អាចនិយាយបានថា នៅក្នុងខ្លួនគាត់ ក៏ដូចនៅក្នុងកម្មាភិបាលកសិករជាទូទៅ ពេលគេកាន់អំណាច ឬកាន់កាំភ្លើងហើយ ជាទូទៅ ទោះបីតិចឬច្រើន គិតគូរតាមរបៀបសក្តិភូមិហើយ។ តែប៉ុលពតជឿថា មនុស្សយើងម្នាក់ៗតែងតែវិវត្តន៍។ បញ្ហានៅត្រង់ជួយឲ្យគាត់វិវត្តន៍ទៅតាមទិសកាន់តែល្អឡើងៗ។ ដូច្នេះនៅគ្រប់តែពេលដែលលោកនិយាយពីគាត់ ប៉ុលពតតែងនិយាយពីចំណុចខ្លាំងរបស់គាត់មិនដែលខានទេ គឺចំណុចខ្លាំងខាងពិសោធន៍ជាក់ស្តែង ខាងសកម្មប្រយុទ្ធ។ ប៉ុន្តែគាត់ក៏មិនដែលភ្លេចរំលឹក ពីការចាំបាច់ត្រូវបំពាក់ថែមនូវពន្លឺនៃទ្រឹស្តីបដិវត្តន៍ដែរ។ ដើម្បីជម្រុញឲ្យតាម៉ុក ក៏ដូចជាកម្មាភិបាលកសិករផ្សេងទៀតខំកសាងខ្លួន ឲ្យរីកចម្រើនទៅមុខទៀត ប៉ុលពតបានផ្ញើរបស់ដែលគាត់ហៅថា ការតស៊ូផ្ទៃក្នុងដោយហ្មឹងម៉ាត់ តែដោយអំណត់ព្យាយាមនៅក្នុងចលនាទិទៀន ស្វ័យទិទៀនមិនដែលខានទេ។



## អំពីព្រឹត្តការណ៍មួយចំនួនដែលអ្នកស្រាវជ្រាវខ្លះយល់ខុស ឬមិនបាននិយាយដល់

### ១. អំពីព្រឹត្តិការណ៍មួយចំនួនដែលអ្នកស្រាវជ្រាវខ្លះយល់ខុស

ក-អ្នករងគ្រោះទៅជាអ្នកបង្កសង្គ្រាម ឯអ្នកបង្កសង្គ្រាមទៅជាអ្នករងគ្រោះ

នៅពីខាងដើម ពេលដែលខ្ញុំនិយាយពីកំណត់ហេតុថ្ងៃ១៤ ឧសភា ១៩៧៦ របស់គណៈអចិន្ត្រៃយ៍ ប.ក.ក ខ្ញុំបានកត់សម្គាល់ថា លោកបែន គៀរណាន់ បានយល់ថា ចំពោះប៉ុលពតការចរចាមិនសំដៅដោះស្រាយបញ្ហាជាក់ស្តែងទេ តែ "ដោះស្រាយបញ្ហាអប់រំ" ទៅវិញ។ ហើយលោកបន្ថែមថា ឯមេរៀនគឺថា "ចរចាជាមួយវៀតណាមមិនបានទេ..."។ នេះជាការសរុបទស្សនៈរបស់ លោកបែន គៀរណាន់ចំពោះកំណត់ហេតុថ្ងៃ១៤ ឧសភា ១៩៧៦ របស់គណៈអចិន្ត្រៃយ៍ ប.ប.ក។ ដូច្នេះចំពោះលោក បែន គៀរណាន់ ឯកសារនេះទៅជាភស្តុតាងនៃនយោបាយបង្កសង្គ្រាមរបស់លោកប៉ុលពតទៅវិញ។

នេះជាឧទាហរណ៍មួយច្បាស់នៃការយល់ខុស។ មិនត្រឹមតែយល់ខុសល្មមទេ គឺយល់ផ្ទុយពីការពិត។

ចំពោះគាត់ កំណត់ហេតុនេះបែរជាបង្ហាញថា ប៉ុល ពតចាំតែរៀបចំសង្គ្រាម ជាមួយវៀតណាមទេ។ អ្នករងគ្រោះទៅជាអ្នកបង្កសង្គ្រាម ឯអ្នកបង្កសង្គ្រាមទៅជាអ្នករងគ្រោះ។

ឯការពិតកំណត់ហេតុនេះបង្ហាញច្បាស់ថា ៖

ទី១ គណៈអចិន្ត្រៃយ៍ទាំងអស់ដែលមានមុខនៅទីនោះ មានការព្រួយបារម្ភខ្លាំងដោយដឹងថាវៀតណាម ច្បាស់ជាមិនថយទេ ក្នុងការទាមទាររបស់គេនេះ ដោយគេអាងថាគេជាប្រទេសធំ។ ដូច្នេះទាំងអស់គ្នាសម្លឹងមើលទៅ

មុខឃើញខ្មៅ ឃើញការតានតឹង និងការវាយគ្នាតាមព្រំដែនជាប់ហើយ។ ដូច្នេះម្នាក់ៗគិតតែរកវិធីយ៉ាងដូចម្ដេចដើម្បីចៀសវាងការតានតឹង ហើយកុំឲ្យមានរឿងតាមព្រំដែន។ សុខចិត្តទទួលយកព្រំដែនបច្ចុប្បន្នដែលមិនទាន់ច្បាស់ល្អជាជាងជជែកគ្នាឡើងចុះៗ។

ទី២ ឯប៉ុលពតវិញមុននឹងនិយាយវែងឆ្ងាយទៅមុខទៀត គាត់ថាគាត់អត់មានអ្វីថែមលើអ្វីដែលទាំងអស់គ្នាបាននិយាយមកហើយទេ។ មានន័យថាគាត់យល់ស្របតាមការ ព្រួយបារម្ភនិងការគិតគូរទាំងនោះហើយ។ ទើបគាតនិយាយថា៖ "មានទំនាស់កុំរៃជាមួយវៀតណាម" ហើយគាត់ក៏បន្តទៀតថា៖ "បច្ចុប្បន្ន និង តទៅអនាគតទៀតនឹងចេះតែមានរឿងជាប់ហើយ។ យើងត្រូវពង្រឹងគោលជំហរយើង... តទៅអនាគត បើយើងចាប់ពិសោធន៍នេះឲ្យជាប់ យើងចចាជាមួយនរណាក៏បានដែរ។ ដូច្នេះជាមេរៀនមួយធំណាស់..."។ ពីខាងលើ ខ្ញុំបានវៃន័យពាក្យនេះរបស់គាត់រួចហើយ។ គាត់ចង់មានប្រសាសន៍សំដៅទៅពួកកម្មាភិបាល ដែលចេញមកពីសង្គ្រាម៩ឆ្នាំក្នុងនេះរួមទាំង សូភឹមផង តែដោយប្រយោល មិនបញ្ចេញឈ្មោះ ប៉ុន្តែក៏ច្បាស់លាស់ណាស់ដែរថាកុំចិញ្ចឹមសេចក្ដីសង្ឃឹមលើវៀតណាមទៀត ហើយសុំឲ្យឈប់ទាក់ទងសហការណ៍ជាមួយវៀតណាមទៅ។ ពាក្យដែល ប៉ុលពតនិយាយថា"នេះជាមេរៀនមួយធំណាស់" គាត់ចង់មានប្រសាសន៍ថា៖ "តើទាំងអស់គ្នាឃើញទេ តើវៀតណាមគិតគូរផលប្រយោជន៍ជាតិយើងទេ? គិតគូដល់ផលប្រយោជន៍ទាំងអស់គ្នា ទៅវិញទៅមក ឬមួយគិតតែកេងចំណេញលើយើងគ្រប់តែជំហាន?" នេះជាសេចក្ដីអំពាវនាវឲ្យទាំងអស់គ្នាឃើញបញ្ហានេះឲ្យច្បាស់ ហើយបែរមកពង្រឹងពង្រីក សាមគ្គីភាព ឯកភាពផ្ទៃក្នុងបក្សវិញ ដោយឈរលើមូលដ្ឋានគោលជំហរឯករាជ្យ ម្ចាស់ការរបស់ ប.ក.ក.វិញ។ មុននេះបន្តិច គាត់ក៏បានព្រមានហើយដែរ តែដោយប្រយោល ដោយនិយាយពីប្រទេសផ្សេងទៀត ដែលត្រូវគេគំរាម កំហែងដូចគ្នា ដូចជា (រុស្ស៊ី កាលពីឆ្នាំ ១៩២០-២១) ដូចជាអាល់បានី .... ដោយ



គាត់មានប្រសាសន៍ថា៖ "វាយពីក្រៅមិនងាយទេ... លើកលែងតែមានកម្លាំងខាងក្នុងគ្រប់គ្រាន់ដើម្បីឧបត្ថម្ភការឈ្លានពានពីក្រៅ" ហើយគាត់ក៏បន្ថែមទៀតថា៖ "កំទេចកម្លាំងប្រឆាំងពីខាងក្នុងជាបុព្វសិទ្ធសំខាន់ជាងគេ"។ ពេលនោះ លោកសូភឹមមិនបានចូលរួមប្រជុំផងទេ ។ ជាហូរហែមក លើកលែងតែអង្គប្រជុំធំៗ ដូចជាប្រជុំមជ្ឈឹម ឬសន្និបាត គាត់មិនសូវបានមកចូលរួមប្រជុំទេ ដោយគាត់សំអាងថាគាត់ឈឺ។ ពេលនោះ ខ្ញុំក៏ឮសំដីលោក ប៉ុលពត យ៉ាងនេះដែរ តែខ្ញុំមិនដឹងថាមានទំនាស់ផ្ទៃក្នុងដល់កម្រិតនេះ។ ពេលនោះខ្ញុំយល់ឃើញថាមិនមានខ្មែរណាទៅចូលរួមគាំទ្រវៀតណាម ក្នុងរឿងឱសានុវាទនេះទេ ក៏ដូចក្នុងរឿងសហព័ន្ធ ឥណ្ឌូចិនជាទូទៅដែរ។ ដូច្នេះខ្ញុំមិនព្រួយបារម្ភពីរឿងផ្ទៃក្នុងទេ។ ខ្ញុំព្រួយបារម្ភតែពីរឿងវាយគ្នានៅព្រំដែន ហើយខ្ញុំក៏យល់បញ្ហាឱសានុវាទនេះមិនអស់ដែរ។

ចំពោះអ្នកស្រាវជ្រាវផ្សេងទៀត គឺគ្មានអ្នកណាចាប់អារម្មណ៍ដល់ឯកសារនេះទាល់តែសោះ។ ដូច្នេះក៏មិនមានអ្នកណាមើលឃើញឱសានវាទ ខែឧសភា ឆ្នាំ១៩៧៦ របស់វៀតណាមទេ ហើយក៏មិនបានមើលឃើញការសម្រេចរបស់គណៈអចិន្ត្រៃយ៍ ប.ប.ក ថាខិតខំរក្សាព្រំដែនបច្ចុប្បន្នឲ្យបាន ហើយខិតខំជៀសវាងកុំឲ្យមានការតឹងតែងអ្វីឲ្យសោះជាមួយវៀតណាម។ គេបែរជាយល់ថា អ្នកដឹកនាំខ្មែរក្រហមស្រវឹងនឹងជ័យជម្នះ ហើយប្រកាន់នយោបាយមួយបង្ករឿងជាមួយវៀតណាម ដែលខ្លាំងជាងខ្លួន លើសលុប ដោយមិនមើលមាឌខ្លួនឯងទៅវិញ។ គេមើលមិនឃើញគំនុំរបស់វៀតណាមចំពោះគោលជំហរឯករាជ្យ-អធិបតេយ្យ របស់ប៉ុលពតហើយបែរជាយល់ថា ការលើកឡើងរបស់ប៉ុលពត និង អ្នកដឹកនាំខ្មែរក្រហមផ្សេងទៀត អំពីកម្ពុជាត្រូវត្រៀមខ្លួន ដើម្បីប្រឈមមុខទល់នឹងគ្រោះអាសន្ននៃមហិច្ឆតាវៀតណាមក្នុងរយៈពេលដ៏ខ្លីខាងមុខនេះគ្រាន់តែជាលេស ដើម្បីបិទបាំងមនោគមវិជ្ជានិយមជ្រុលរបស់ខ្លួន និងនយោបាយរបស់ខ្លួន ដែលទៅរករឿងអ្នកជិតខាងទៅវិញ។ អ្នកនិពន្ធខ្លះភ័ន្តច្រឡំថា ការដែលមេៗខ្មែរក្រហមទៅវាយភូមិវៀតណាមនៅតាមព្រំប្រទល់ ជាបាតុភាពនៃនយោបាយងងឹតងងល់មួយ "ដែលប៉ុនប៉ង

ទៅដណ្តើមកម្ពុជាក្រោមមកវិញ។ ប៉ុន្តែកំណត់ហេតុអង្គប្រជុំ ថ្ងៃ១៤ឧសភា នៃគណៈអចិន្ត្រៃយ៍ប.ប.ក បានបង្ហាញច្បាស់ថាសមាជិកម្នាក់ៗ នៃអង្គប្រជុំគ្មានសំណូមពរអ្វីក្រៅពីរក្សាព្រំដែនបច្ចុប្បន្ននេះឲ្យបានទាល់តែសោះ ហើយព្រួយបារម្ភខ្លាចតែរក្សាប៉ុណ្ណឹង មិនបានព្រួយបារម្ភខ្លាចតែវៀតណាមមកបុករុកតាមព្រំដែនបង្កឲ្យមានរឿងតឹងតែងតែប៉ុណ្ណោះ។ ឯកសារនេះជាកំណត់ហេតុផ្ទៃក្នុងមិនមែនសម្រាប់យកទៅផ្សាយទេ។ ដូច្នេះវាមានតម្លៃណាស់ គួរឲ្យជឿបានពេញទីអំពីពាក្យមួយម៉ាត់ៗរបស់មេៗ ខ្មែរក្រហមនៅក្នុងឯកសារនោះ។

## ខ-ប៉ុលពតរួមជាមួយតាម៉ុក និងកែពកប្រឆាំងសូ ភឹម?

អ្នកស្រាវជ្រាវជាច្រើនសរសេរថា ក្នុងក្របខណ្ឌនៃការខិតខំប្រឹងប្រែងរបស់គាត់ប្រឆាំងវៀតណាម ប៉ុលពតបានរួមជាមួយតាម៉ុក និងកែ ពក ប្រឆាំងនឹងសូ ភឹម។ យល់យ៉ាងនេះក៏ជាការខុសធំមួយទៀត។ ប៉ុលពតមិនអាចលេងល្បែងបក្សពួកយ៉ាងនេះទេ។ ល្បែងនេះនឹងធ្វើឲ្យអន្តរាយដល់ប.ក.ក និងប្រទេសទាំងតមូលជាមិនខានទេ ពិសេសក្នុងពេលសង្គ្រាម។ រហូតដល់ឆ្នាំ១៩៧៥ គាត់ជានិមិត្តរូបជាទីគោរពនៃមាគ៌ារបស់ ប.ក.ក។

យើងបានឃើញហើយថា ប.ក.ក ចេញមកពីកម្លាំងពីរដែលមានកំណើតដើមខុសគ្នាក្នុងសង្គមខ្មែរ។ ដើម្បីផ្សាភ្ជាប់កម្លាំងទាំងពីរខុសផ្សេងគ្នានេះឲ្យទៅជាសាច់មួយជាមួយគ្នាក្នុងបក្សតែមួយ ជាការលំបាកបំផុតដែលប៉ុលពតបានខិតខំណាស់។ ខិតខំដំបូងបង្អស់ដោយពុះពាររៀបចំមាគ៌ា និងលក្ខន្តិកៈរបស់បក្សខ្មែរមួយឯករាជពីវៀតណាម។ តមកទៀតរៀបចំបានហើយត្រូវដឹកនាំកម្លាំងទាំងពីរផ្ទែកតស៊ូដោយ "ប៉ិនប្រសប់បំផុត" ដោយឈរលើមាគ៌ា និងលក្ខន្តិកៈនេះឲ្យរឹងមាំទៀត ទើបបង្កបង្កើតលក្ខណៈសម្បត្តិបានដើម្បីឲ្យក្រុមទាំងពីរសាមគ្គីគ្នាបាន។

ក្រោយរដ្ឋប្រហារខែមីនាឆ្នាំ១៩៧០ កម្លាំងពួកកុម្មុយនីស្តវៀតណាមបានសម្រុកចូលមកស្រុកខ្មែរ ដោយមិនបានគិតគូដល់មតិរបស់ពួកខ្មែរក្រហម



ទេ។ គេបានចូលមកវាយទីរួមខេត្តមួយចំនួនរបស់លោកលន់ នល់ តាំងពីថ្ងៃ ២០-២១មីនា ឆ្នាំ១៩៧០ គឺមុនការផ្សាយសេចក្តីអំពាវនាវរបស់សម្តេចនរោត្តម សីហនុថ្ងៃ២៣ មីនាម្ល៉េះ។ ចាប់តាំងពីពេលនោះមក ខ្មែរក្រហមព្រួយបារម្ភកាន់តែខ្លាំងពីគ្រោះអាសន្នពួកកុម្មុយនីស្តវៀតណាម ឆ្លៀតឱកាសរដ្ឋប្រហារដើម្បីត្រឡប់មកត្រួតត្រាចលនាតស៊ូខ្មែរវិញ ដូចកាលពីជំនាន់វៀតមិញ។ គឺចាប់តាំងពីពេលនោះមកហើយ ដែលការព្រួយបារម្ភនេះជិតដាមជាប់ជានិច្ចក្នុងគំនិត និងក្នុងមាគ៌ានយោបាយ និងការសម្រេចផ្សេងៗរបស់ប.ក.ក។

កាលពីគាត់ជួបលោកឡេ យន់នៅហាណូយ លោកសាឡុតស បានជម្រាបគាត់រួចហើយថា ខ្មែរត្រូវការអាវុធ តែមិនត្រូវការទ័ពទេ ហើយថា គេនឹងកសាងកងកម្លាំងប្រដាប់អាវុធដោយខ្លួនគេ ជាជាងពឹងផ្អែកលើវៀតណាម។ ប៉ុន្តែពេលគាត់មកដល់ក្នុងប្រទេស កម្លាំងកុម្មុយនីស្តវៀតណាមចូលជ្រៅក្នុងប្រទេសរួចស្រេចទៅហើយ។ ស្ថិតនៅចំពោះមុខសភាពការណ៍យ៉ាងនេះ គាត់ត្រូវការដឹងសភាពការណ៍ល្អិតនៅតាមភូមិភាគនីមួយៗ។ ដូច្នេះហើយបានជានៅចុងខែកញ្ញា ១៩៧០ ក្រោយពីបានក្តាប់សភាពការណ៍ធំៗ និងដោះស្រាយបញ្ហារួមមួយចំនួននៅឰសានហើយ គាត់ប្រញាប់ប្រញាល់អញ្ជើញកម្មាភិបាលណា ដែលអាចមកបានឲ្យមកម្តុំស្ទឹងជិនិតព្រំប្រទល់ខេត្តកំពង់ធំ-កំពង់ចាម។ គាត់កំពុងតែធ្វើដំណើរពីរតនៈគីរីចុះទៅរកបោះទីតាំងនៅខ្ទែងនោះ ដើម្បីងាយស្រួលទាក់ទងដឹកនាំជាងនៅឰសាន។ គេមិនមានឯកសារអ្វីដើម្បីដឹងច្បាស់ថា តើនរណាខ្លះបានចូលរួមនោះទេ។ ទោះបីថ្ងៃក្រោយមកប៉ុលពតបានប្រកាសថា ជាការប្រជុំគណៈអចិន្ត្រៃយ៍ក៏ដោយ នៅពេលនោះអ្នកដែលមានមុខនៅទីនោះ ប្រហែលមានតែខ្លួនគាត់ នួន ជា និងសូភឹមទេ។ អ្នកស្រាវជ្រាវបានខ្វែងមត្តិគ្នាលើឈ្មោះអ្នកទី៣ដែលបានចូលរួមប្រជុំនៅពេលនោះ។ អ្នកខ្លះគិតថា អាចកុយ ធួន។ លទ្ធភាពនេះក៏អាចមានពីព្រោះកុយ ធួន ជាម្ចាស់ភូមិភាគនោះ។ តែពេលនោះលោកកុយ ធួននៅមិនទាន់ជាសមាជិកគណៈមជ្ឈឹមនៅឡើយផងទេ។ ផ្ទាល់ខ្លួនខ្ញុំ ខ្ញុំនៅតែលំអៀងទៅជឿថា ប្រហែលជាសូភឹម ពីព្រោះភូមិភាគបូព៌ានៅជាប់និងវៀតណាម

ជាងគេ ហើយមានពិសោធន៍ពីឆ្នាំ១៩៦៨ រួចម្តងមកហើយ។ ឯកភាពគ្នារួចអស់ហើយ យកថ្ងៃ១មករាជាថ្ងៃផ្ទុះអាវុធ។ ដល់ថ្ងៃកំណត់ស្រាប់តែមិនឃើញខាងបូព៌ារួមជាមួយគេ។ ឃើញថា នៅទីនោះមានការលំបាកក្នុងការទប់ទល់ឥទ្ធិពលវៀតណាមជាងគេ។ ដូច្នេះដល់ក្រោយរដ្ឋប្រហារ ប៉ុលពតចង់ដឹងសភាពការណ៍ខាងបូព៌ាមុនគេ។ ប៉ុលពតប្រកាសថា ជាការប្រជុំគណៈអចិន្ត្រៃយប្រហែលជា ដើម្បីគូសបញ្ជាក់អំពីសារៈសំខាន់នៃសេចក្តីសម្រេចចិត្តដែលបានអនុម័តនៅពេលនោះ។ គឺជាការប្រកាសរំលឹកអំពីគោលជំហរឯករាជ្យម្ចាស់ការ ដែលបានចេញមកពីមេរៀននៃកិច្ចព្រមព្រៀងហ្សឺណែវឆ្នាំ១៩៥៤ គោលជំហរដែលនឹងត្រូវខ្ចាយទៅជាពាក្យស្លោករបស់ ប.ក.ក ក្នុងរយៈពេល៩ឆ្នាំក្រោយតរហូតមកទៀត គឺថា:

"យើងមិនត្រូវអនុញ្ញាតឲ្យរដ្ឋដទៃសម្រេចវាសនាជាតិយើង ប្រជាជនយើង និងបដិវត្តន៍យើងជាដាច់ខាត។ បច្ចុប្បន្ននេះ (រដ្ឋទាំងនោះ) នៅចិញ្ចឹមគោលបំណងចាស់របស់គេ...។ មិនត្រូវឲ្យកំហុសជាប្រវត្តិសាស្ត្រមកហើយនោះត្រឡប់មកវិញម្តងទៀតទេ។ ជំនួយមកពីក្រៅទោះបីល្អយ៉ាងណាក៏ដោយមិនមានលក្ខខណ្ឌក៏ដោយ... មិនអាចជាកត្តាសម្រេចទេ...។ យើងត្រូវតែឈរលើគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ហើយទ្រាំទ្រលំបាកវេទនាឲ្យរឹងមាំជាប់ជានិច្ច។ ឈរលើមូលដ្ឋាននេះ ជំនួយណាយើងទទួលជំនួយណាយើងមិនទទួល អាស្រ័យលើយើងឃើញថា តើមានប្រយោជន៍ដល់យើងឬមិនមាន និងលើវិធីដែលគេប្រើប្រាស់ជំនួយនោះយ៉ាងណា"។[២០៩]

គឺឈរលើសេចក្តីសម្រេចចិត្តនេះហើយដែលនៅឡើសាន សូម្បីតែសាលាយោធាដើម្បីហ្វឹកហ្វឺនយោធា និងបច្ចេកទេសផ្សេងៗ ក៏គេបដិសេធ។

ឯសភាពការណ៍នៅបូព៌ាពេលនោះ ក៏ដូចប៉ុលពតបានព្រួយបារម្ភមែនៗ សូ ភឹមមិនអាចទប់ទល់កម្លាំងសង្កត់របស់វៀតណាមបានទេ។ លើបញ្ហានេះ ទា សំប៊ុន កម្មាភិបាលមួយរូបនៃភូមភាគបូព៌ាបានរៀបរាប់ដូចតទៅ៖

២០៩ ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ២១៣



"នៅឆ្នាំ១៩៧០ ពួកកុម្មុយនីស្តវៀតណាមចូលកម្ពុជា ដើម្បីវាយពួកលន់នល់ ហើយរំដោះដីបានធំទូលាយ។ ដំបូងឡើយគេបានសួរមតិសូ ភឹមដែរ តែដំបូងយើងមិនយល់ស្របទេ ពីព្រោះជាប្រទេសយើង។ យើងសុំតែកាំភ្លើងទេ។ ប៉ុន្តែគេថា បើយើងមិនព្រម នាំឲ្យអន្តរាយដល់ប្រទេសគេ។ ដូច្នេះទោះបីយ៉ាងណាក៏ដោយ គេនៅតែចូលហើយ។ គេបន្ថែមថា បើគ្មានគេជួយទេ យើងក៏មិនអាចរំដោះប្រទេសយើងបានដែរ"។

ការពិតទៅក្នុងសភាពការណ៍ ដែលវៀតណាមត្រូវអាមេរិកដេញពីក្រោយ ហើយទោះបីយ៉ាងណាក៏ដោយ កម្ពុជាក៏ពុំអាចរាំងបានដែរ។ ប៉ុន្តែបើទប់មិនបាន ហើយខាងខ្មែរនៅរក្សាឯករាជភាពរបស់ខ្លួនតាមមេរៀនដែលទាំងអស់គ្នាបានរៀនសូត្រ ពីកិច្ចព្រមព្រៀងហ្សឺណែវឆ្នាំ១៩៥៤ទៅ ហើយវង់ចាំពីគ្រោះពីភាក្សាគ្នាឲ្យឯកភាពផ្ទៃក្នុងបក្សខ្មែរសិន ប្រហែលជាមិននាំឲ្យមានការស្មុគស្មាញទៅពេលក្រោយទេមើលទៅ។ មិនដូច្នេះសូភឹមបានសម្រេចដោយឯកតោភាគី។ លើសភាពការណ៍នេះ ទា សំប៊ុន បានរៀបរាប់ដូចតទៅ៖

"តាំងពីពេលនោះមក យើងទៅជាមិត្តរាប់អានគ្នាជិតស្និតណាស់។ យើងទៅណាមកណាក៏ជាមួយគេ។ យើងទទួលកាំភ្លើងដែលគេដណ្តើមបានមកឲ្យទាហានយើង។ យើងពង្រីកដល់វរៈសេនាធំ"។

រឿងខាងលើនេះ ខ្ញុំបានដឹងដោយសារតែខ្ញុំបានអានសៀវភៅរបស់លោកបែន គៀរណាន់ទេ។[២១០]

តមកទៀត វៀតណាមក៏បើកសាលាយោធា សាលាពេទ្យ សាលារដ្ឋបាល សាលាវិទ្យាទាក់ទង ដើម្បីកសាងកម្មាភិបាលរបស់ភូមិភាគ។ លោកសូ ភឹមប្រហែលគិតថា ពិតមែនហើយគណៈបញ្ជាការរួមយើងមិនអាចយល់ព្រម

២១០ បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ៣១១

បានទេ តែបើគង់តែទប់គេមិនឲ្យចូលក្នុងប្រទេសមិនបានដដែលទេ មិនមានហេតុផលអ្វី ដើម្បីរារាំងមិនឲ្យវៀតណាមជួយកសាងកម្មាភិបាលខាងបច្ចេកទេសទេ។

### គ-ដូច្នេះទំនាស់រវាងមាគ៌ាពីរនេះជ្រាលជ្រៅណាស់

ចំពោះសូ ភឹម គាត់អាចយល់ថា អង្គការផ្សេងៗរបស់គាត់បានចំណេញពីការ ដែលគាត់បានសម្រួលទៅតាមកម្លាំងសង្កត់របស់ពួកកុម្មុយនីស្តវៀតណាម ច្រើនជាងកាលពីឆ្នាំ១៩៦៨ទៅទៀត។

ប៉ុន្តែចំពោះប៉ុលពតវិញគាត់ឃើញថា សម្រួលជាមួយវៀតណាមដូច្នេះ គឺម្យ៉ាងវាផ្ទុយនឹងការសម្រេចចិត្តរបស់បក្សហូរហែមកមានជាអាទិ៍ការសម្រេច ក្រោយពេលដែលបានរៀនសូត្រដកពិសោធន៍លើកិច្ចព្រមព្រៀងហ្សឺណែវឆ្នាំ១៩៥៤ ម្យ៉ាងទៀតនឹងនាំឲ្យមានបច្ច័យវែងឆ្ងាយទៅថ្ងៃក្រោយទៀតជាមិនខានទេ។ នៅកន្លែងផ្សេងៗទូទាំងប្រទេសវៀតណាមមានចាត់តាំងកងទ័ព និងរដ្ឋអំណាចភូមិឃុំដែរ ប៉ុន្តែដោយកម្មាភិបាលទទួលខុសត្រូវនៅនឹងកន្លែងមិនបានដឹងផងទេ។ ដូច្នេះការចាត់តាំងទាំងនោះ ប.ក.ក អាចទារមកវិញហើយរំលាយចោលបាន។ នៅភូមិភាគបូព៌ានៅឆ្នាំ១៩៧១ មុនសាលាទាំងនោះត្រូវបិទកម្មាភិបាលយោធា និងផ្នែកផ្សេងទៀតមួយចំនួនបានចេញមកបម្រើការងារហើយស្រេច។ ប.ក.ក មិនអាចរំលាយ ឬបណ្តេញចោលដូចកន្លែងផ្សេងទៀតបានទេ។ ទោះបីយ៉ាងនេះក៏ដោយ ប៉ុលពត មិនបានទៅចងសម្ព័ន្ធភាពពិសេសណាមួយដើម្បីប្រឆាំងនឹងសូ ភឹមទេ។ ការភ្ជាត់ភ្ជាំងតែមួយជំហានពីសំណាក់ខាងគាត់នឹងនាំឲ្យមានសង្គ្រាមបំបែកទឹកដី។ អ្វីដែលគាត់អាចធ្វើបានមានតែក្រុមដឹកនាំទាំងអស់ ដោយមានសូ ភឹមរួមជាមួយផង ខិតខំអប់រំឲ្យកម្មាភិបាលទាំងនោះឲ្យជ្រួតជ្រាបមាគ៌ានយោបាយឯករាជ្យម្ចាស់ការរបស់ ប.ក.កតែប៉ុណ្ណោះ។ ឯអប់រំបានមិនបានកម្រិតណានោះ គឺជារឿងមួយផ្សេងទៀត។ ខ្ញុំបានឃើញប៉ុលពតយកចិត្តទុកដាក់ខំអូសទាញសូភឹមណាស់ ហើយសម្តែងនូវការគោរព ចំពោះ



គាត់ជាទីបំផុត។ នៅឱកាសដែលខ្ញុំចេញទៅអឺរ៉ុប ឬទៅញូយ៉ក គាត់បានណែនាំឲ្យខ្ញុំរកទិញថ្នាំ ដើម្បីព្យាបាលរោគរមាស់ ដែលចេញពេញខ្លួនគាត់នាំឲ្យរំខានគាត់ជាខ្លាំង។ ហើយមួយដើងៗខ្ញុំ បានទិញហឺជ្រូករទីហ្សូនជូនគាត់ទាំងកញ្ចប់ៗ។ ប៉ុន្តែខ្ញុំមិនបានដឹង អំពីការព្រួយបារម្ភរបស់ប៉ុលពតទេ។ រហូតដល់ថ្ងៃដែលខ្ញុំបានអានការកត់សម្គាល់របស់គាត់ អំពីចក្រី នៅថ្ងៃ ៩ តុលា ១៩៧៥ នៅក្នុងសៀវភៅរបស់លោកបែន គៀរណាន់។ តាមខ្ញុំយល់ពេលនោះប៉ុលពតចង់សម្តែងការព្រួយបារម្ភ ដែលគាត់មានតាំងពីយូរមកហើយ មិនចំពោះតែកងទ័ពរបស់ចាន់ចក្រីទេ គឺចំពោះកងទ័ពបូព៌ា ជាទូទៅតែម្តង។ ការអប់រំខាងនយោបាយដល់យុទ្ធជនមិនបានជ្រៅទេ ពីព្រោះគេជិតស្និតជាមួយវៀតណាម ប៉ុន្តែគេមើលងាយយុទ្ធមិត្តនៅភូមិភាគផ្សេងទៀតដោយហៅគេថា ពួកក្អែកទឹក ហើយគេសហការណ៍ជាមួយវៀតណាមក្លែងខ្លួនធ្វើជាខ្មែររំដោះវាយខ្មែរគ្នាឯងទៀត វាយបក្សឯងទៀត។ កាលពីសង្គ្រាម ប៉ុលពតមិនអាចលើករឿងនេះបានទេ ពីព្រោះត្រូវជៀសវាងកុំឲ្យទំនាស់រីករាលដាល។ ប៉ុន្តែគាត់ឃើញថា ការប្រមាតមើលងាយកងទ័ពគ្នាឯងនេះ ខ្មែរនឹងខ្មែរវាយគ្នានេះ រឿងទាំងអស់នេះចេញមកពីបរទេសហើយនាំឲ្យកើតមានទំនាស់ផ្ទៃក្នុងបក្សឯង កងទ័ពឯង ពិសេសរវាងភូមិភាគទាំងបីដែលនៅជាប់គ្នា គឺភូមិភាគបូព៌ា ភូមិភាគនិរតី និងភូមិភាគឧត្តរ។

តាមដែលខ្ញុំដឹង លោកបែន គៀរណាន់ ជាអ្នកនិពន្ធដែលបានសរសេរអំពីទំនាស់រវាងភូមិភាគទាំងបី ដែលនៅជិតខាងគ្នានេះ ពិស្តារជាងគេ។

អំពីការទាក់ទងរវាងភូមិភាគឧត្តរ និងបូព៌ា លោកបានផ្អែកលើការរៀបរាប់របស់ប៉ុន ដែលជាទាហាន ដែលវៀតណាមបានជ្រើសរើសតាំងពីថ្ងៃដំបូងដែលគេចូលមកកម្ពុជា ហើយក្រោយមកបានធ្វើការជាអ្នកបកប្រែឲ្យវៀតណាម ក្នុងការទាក់ទងរបស់គេជាមួយពួកកុម្មុយនីស្តខ្មែរនៅបារាយ (ខេត្តកំពង់ធំ)។ ប៉ុននិយាយថា នៅត្រើយខាងណោះទន្លេមេគង្គ (ភូមិភាគឧត្តរ) ពួកខ្មែរក្រហមមិនអនុញ្ញាតឲ្យស្លៀកពាក់ខោអាវព៌ណទេ។ នៅខាង

ណោះគេអនុញ្ញាត។ នៅត្រើយខាងណោះ ពួកគេចង់ដឹងថាហេតុម្តេច បានជាខាងណោះមិនគោរពវិន័យរបស់អង្គការ ហើយគេបាញ់ពួកដែលមកពីខាងណោះ។ ពីខាងត្រើយទន្លេម្នាក់គេស្អប់គ្នាទៅវិញទៅមកខ្លាំងណាស់។[២១១]

ដើម្បីផ្តល់ឧទាហរណ៍ពីការចាប់ផ្តើមរឿងដំបូង ក្នុងទំនាស់រវាងនិរតី និងបូព៌ា អ្នកនិពន្ធដដែលនេះបានសម្ភាសន៍ឥស្សរជនម្នាក់ ដែលកាលពីឆ្នាំ១៩៧៣ ជាបញ្ជាការកងវរៈសេនាធំលេខ១២៦នៃភូមិភាគបូព៌ា។ នៅពេលដែលកងនេះកំពុងជាប់ដៃដេញកងទ័ពលន់ នល់ គេក៏ឆ្លងទន្លេមេគង្គចូលទៅក្នុងភូមិភាគពិសេសរបស់វនវេត។ នៅឯនាយទៅទៀត គឺជាភូមិភាគនិរតីរបស់តាម៉ុក។ ឥស្សរជនរូបនេះនិយាយថា ពេលកងទ័ពខ្ញុំមួយចំនួនឡើងទៅភ្នំជីសូ (ព្រំប្រទល់និរតី និងតំបន់២៥) រកថ្នាំបូរាណសម្រាប់ព្យាបាលយុទ្ធជនគ្រុនចាញ់ ពួកនិរតីបានចាប់គេ១២នាក់យកទៅឆ្ងាយ ហើយសម្លាប់ចោលបាត់។ ឥស្សរជននោះថា គាត់បានបញ្ជូនដំណាងឲ្យទៅជួបតាម៉ុក ហើយបានជម្រាបមេគាត់ៗ ក៏បានសរសេរទៅតាម៉ុកទៀតសុំឲ្យដោះលែងយុទ្ធជនទាំងនោះ។ តែតាម៉ុកនៅតែប្រកែកថា មិនដឹងៗ។ ហើយឥស្សរជននោះក៏បន្ថែមថា លេខាតំបន់២៥ ជ័យ (ឈ្មោះដើម នន សួន) ធ្វើការជាមួយក្រុមខ្ញុំមិនមានបញ្ហាទេ ប៉ុន្តែម៉ុក និងជ័យក៏មិនសូវត្រូវគ្នាដែរ។

អ្នកនិពន្ធក៏បានដកស្រង់ពីលោកកេណោតគ្វីន ដែលលោកបានផ្អែកលើប្រភពផ្សេង តែអាចនិយាយពីរឿងតែមួយនេះដដែល។ លោកកេណោតគ្វីនថា "នៅខែវិច្ឆិកា ឆ្នាំ១៩៧៣ ពួកខ្មែរក្រហមបានចាប់កម្មាភិបាលខ្មែររំដោះនៅជិតអង្គរបូរីបីនាក់យកទៅបាត់ មិនឃើញត្រឡប់មកវិញទេ ប្រហែលជាយកទៅសម្លាប់ចោល។ ស្អែកឡើងកម្មាភិបាលខ្មែរក្រហមមកពីតំបន់២៥ (ខេត្តកណ្តាល) ជួបជាមួយខ្មែររំដោះពីតំបន់២៤ (ព្រៃវែង)។ ពួកខ្មែរក្រហមសុំឲ្យពួកខ្មែររំដោះឈប់សហការជាមួយពួកវៀតកុង និងពួក

២១១ បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ៣៣១



វៀតណាមខាងជើងនៅតំបន់២៤។ ពួកខ្មែររំដោះមិនព្រម។ ការជជែកគ្នាឡើងដល់តឹងសរសៃករហូតដល់មានការវាយគ្នា។ ពួកខ្មែររំដោះដោយមានកម្លាំងវៀតកុង និងវៀតណាមខាងជើងនៅជិតនោះជួយគាំទ្រផង សម្លាប់ពួកខ្មែរក្រហមអស់៤២នាក់ ហើយដេញ អ្នកដែលនៅសេសសល់ឲ្យត្រឡប់ទៅវិញ។ តាំងពីពេលនោះមកពួកខ្មែរក្រហម និងខ្មែររំដោះឆ្លងទន្លេមេគង្គទៅវាយគ្នានៅក្នុងដីគ្នាទៅវិញទៅមកជាប់។[២១២]

អ្នកនិពន្ធ ក៏បានសម្ភាសន៍អាតីតៈសមាជិកកងវរៈសេនាធំលេខ១១នៃភូមិភាគពិសេសម្នាក់កាលពីឆ្នាំ១៩៨០។ កម្មាភិបាលនេះ បាននិយាយថា អង្គភាពរបស់គាត់បានបោះនៅម្តុំនោះដែរ ហើយក៏ធ្លាប់មានរឿងជាមួយកងខាងបូព៌ាដែរ។ "គេស្លៀកពាក់ខោអាវពណ៌អាចម៍សេះ មិនមែនខ្មៅដូចយើងទេ មួកក៏ខុសពីយើង ហើយគេហៅយើងថា ពួកអាក្អែកទឹក។ គេបាញ់លើយើង ពេលយើងជិះទូកនៅក្នុងទន្លេ ហើយតាំងពីនោះមកមានការបាញ់គ្នាទៅវិញទៅមករហូតទាំងយប់ទាំងថ្ងៃ"។ ទាហាននោះថាការវាយគ្នានេះបន្តរហូតដល់សង្គ្រាមចប់នៅខែមេសា ១៩៧៥។[២១៣]

សូមរំលឹកថា "ពួកខ្មែររំដោះ" គឺកងទ័ពចាន់ចក្រីដែលវៀតណាមប្រើឲ្យក្មេងខ្ទង់ធ្វើជាកងទ័ពសីហនុនិយម វៀតណាមនិយម។ គោលបំណងនៃអំពើពុតត្បុតដ៏សែនអាក្រក់នេះ គឺបោកប្រាស់សម្តេច ហើយបំបែកបំបាក់ផ្ទៃក្នុងកម្លាំងតស៊ូជាតិ ចាក់កម្លាំងតស៊ូជាតិពីក្រោយខ្នងដើម្បី កុំឲ្យរំដោះភ្នំពេញបានមុនគេរំដោះព្រៃនគរ។ សូមភ្ជាប់អំពើពុតត្បុតដ៏អាក្រក់នេះ ទៅនឹងសំដីរបស់ឡេ យន់ នៅពេលដែលគាត់ចរចាជាមួយលោកសាឡុតស កាលពីឆ្នាំ១៩៦៥៖

២១២ បែន គៀរណាន់ "របបប៉ុល ពត" ទំព័រ៦៥

២១៣ បែន គៀរណាន់ "របបប៉ុល ពត" ទំព័រ៦៥

"ក្រោយពីវៀតណាមទទួលបានសេរីភាពរបស់ខ្លួន សេរីភាពរបស់កម្ពុជានិងបានមកដោយឯកឯង" ហើយទៅសំដីរបស់កម្មាភិបាលវៀតណាមគ្រប់ថ្នាក់ផ្សេងទៀតដែលគេនិយាយមិនដាច់ពីមាត់គួរឲ្យធុញទ្រាន់។

ដូច្នេះទើបយើងយល់ ហេតុដូចម្តេចបានជាលោកសាឡុតសរខំដោះស្រាយសម្រុះសម្រួលរវាងនិរតីនិងប៉ូពាយ៉ាងណា ក៏ដោះស្រាយមិនបាន។

សភាពការណ៍នេះ ជាសភាពការណ៍ធ្ងន់ធ្ងរបំផុត។ ក្នុងពេលដែលប្រទេសកំពុងមានសង្គ្រាមជាមួយលោកលន់ នល់ និងសហរដ្ឋអាមេរិកទំនាស់ផ្ទៃក្នុងនេះអាចក្លាយទៅជាសង្គ្រាមបំបែកទឹកដីពេលណាក៏បានដែរ។ ក្នុងឋានៈជាអ្នកដឹកនាំកំពូល ប៉ុលពតមិនអាចកាន់ជើងខាងបូព៌ា ដែលទទួលឥទ្ធិពលពីវៀតណាមខ្លាំងពេកនោះទេ។ តែក៏គាត់មិនអាចលេងល្បែង បក្សពួកជម្រុញតាម៉ុក ឬ កែ ពក ឲ្យប្រឆាំងឬបាញ់កងទ័ពខាងបូព៌ាបានដែរ។ ទំនាស់ផ្ទៃក្នុងមិនត្រូវដោះស្រាយដោយអាវុធទេ។ ហូរហែមកឥទ្ធិពលដឹកនាំរបស់គាត់ គ្របដណ្តប់ក្នុងបក្ស ចងក្រងសាមគ្គីឯកភាពផ្ទៃក្នុងបានជាធ្នងមួយធ្នងកាត់បានដោយជោគជ័យឧបសគ្គធំៗ ពីមួយទៅមួយរហូតដល់ពេលនេះ គឺមកពីគាត់ដាច់ខាតឈរលើមាគ៌ា និងលក្ខន្តិកៈរបស់បក្ស ហើយខិតខំតម្រែតម្រង់ឲ្យកម្មាភិបាលទាំងអស់ ពិសេសកម្មាភិបាលសំខាន់ៗដំកល់មាគ៌ាឲ្យខ្ពស់ជាងអ្វីៗទាំងអស់។

ដូច្នេះហើយបានជាខ្ញុំយល់ថា លើចំណុចនេះលោកហ្វីលិព ហ្សូតសរសេរត្រូវ។ ដោយសារការខិតខំប្រឹងប្រែងដឹកនាំរបស់ប៉ុលពត ចលនាបដិវត្តន៍ជាតិមួយពិតប្រាកដ ក៏បានលេចចេញឡើងនៅក្នុងការតស៊ូអាវុធឆ្នាំ១៩៦៨-៦៩។ ប៉ុន្តែការផ្សាំមែកឈើទាំងពីរនេះ នៅតែមិនបានរលាយជាសាច់មួយជាមួយគ្នាបានល្អនៅឡើយ។ សម្ព័ន្ធភាពមួយដែលជៀសមិនផុត ប៉ុន្តែផ្ទុយពីធម្មជាតិនៅបន្តទៅទៀតបាន ដោយសារតែការខិតខំអស់ពីកម្លាំងកាយចិត្ត និងដោយ "ប៉ិនប្រសប់បំផុត" របស់ ស និងសហការីរបស់គាត់។[២១៤]

[២១៤] សូមអានទំព័រ២៣៥ ខាងលើនេះ



### ឃ-តើពេលនោះមាគ៌ាកំណត់ជាម៉េច?

ខាងលើនេះខ្ញុំបានសរសេរថា ប៉ុលពតខិតខំតម្រែតម្រង់ឲ្យកម្មាភិបាលទាំងអស់ ពិសេសកម្មាភិបាលសំខាន់ៗ ដំកល់មាគ៌ាឲ្យខ្ពស់ជាងអ្វីៗទាំងអស់។ តើពេលនោះ មាគ៌ាកំណត់ជាម៉េច?

មហាសន្និបាតឆ្នាំ១៩៧១ (ខ្ញុំបានចូលរួម) បានកំណត់ថា "វៀតណាមជាមិត្តមានទំនាស់"។ ការកំណត់នេះ គឺជាការកំណត់មាគ៌ានយោបាយមួយច្បាស់ចំពោះវៀតណាម។ បានន័យថាគេមិនមែនជាយុទ្ធមិត្តទេ តែក៏មិនមែនជាខ្មាំងដែរ។ ត្រូវអនុវត្តិគោលការណ៍សាមគ្គីតស៊ូ តស៊ូសាមគ្គី។ បើវៀតណាមនៅជាមិត្តហើយ អ្នកផ្សេងទៀតដែលដើរតាមឬគាំទ្រវៀតណាម ក៏នៅតែជាមិត្ត។ ដូច្នេះមិនត្រូវប្រើអាវុធទេ។ បើពិនិត្យតាមមាគ៌ានេះ ឃើញថា សូ ភឹម ក៏ខុស តាម៉ុកក៏ខុស។ សូ ភឹមខុសត្រង់ថាមហាសន្និបាតឆ្នាំ ១៩៧១ បានកំណត់ហើយថា វៀតណាមជាមិត្តមានទំនាស់មិនត្រូវនៅសហការជាមួយវៀតណាមជិតស្និទ្ធទៀតទេ។ តាម៉ុក និង កែពកវិញក៏ខុស គឺត្រង់ប្រើអាវុធក្នុងការដោះស្រាយទំនាស់ជាមួយអ្នកដែលដើរតាមវៀតណាម។ នេះហើយដែលប៉ុល ពត ខំដោះស្រាយឲ្យទាំងអស់គ្នាដំកល់មាគ៌ាឲ្យខ្ពស់ជាងអ្វីៗទាំងអស់។ គឺមាគ៌ានេះហើយដែលវន វេត បានខិតខំអនុវត្តនៅតំបន់២៥ ហើយជាក់ស្តែងគាត់ទទួលបានលទ្ធផលគួរជាទីគាប់ចិត្តដែរ ដូចលោកបែន គៀរណាន់បានសរសេរស្រាប់។[២១៥]

សូមជម្រាបផងដែរថា នៅក្នុងសន្និបាតឆ្នាំ១៩៧១នោះដែរ ក៏មានការសម្រេចមួយទៀតផ្តាច់តំបន់២៥ ពីភូមិភាគបូព៌ា ដើម្បីរួមជាមួយតំបន់១៥នៃភូមិភាគនិរតី បង្កើតជាភូមិភាគមួយថ្មីទៀតហ៊ុមព័ទ្ធភ្នំពេញហៅថា ភូមិភាគពិសេស ហើយប្រគល់ទៅឲ្យវន វេតទទួលខុសត្រូវ។ ឥឡូវនេះក្រោយពីខ្ញុំបានអានបែន គៀរណាន់ទើបខ្ញុំយល់ហេតុម្តេចបានជាប៉ុលពតជ្រើសរើស

[២១៥] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ៣៣៣-៣៣៤

វន វេតឲ្យកាន់ភូមិភាគពិសេស។ គឺមកពីវន វេតទាក់ទងបានល្អទាំងជាមួយតាម៉ុក ទាំងជាមួយសូ ភឹម។ ពេលនោះការទាក់ទងបានល្អរវាងគូទំនាស់ទាំងពីរនាក់នេះជាចំណុចខ្លាំងរបស់គាត់។ តែដល់ឆ្នាំ១៩៧៨ដែលសភាពការណ៍បាក់បែកផ្ទៃក្នុង បានវិវត្តន៍ដល់កម្រិតដែលម្នាងៗលែងនៅជាមួយគ្នាបានទៅហើយ ហើយវនវេតនៅតែខិតខំទាក់ទងល្អជាមួយលោកសូភឹមទៀតនោះ វាទៅជានាំឲ្យអន្តរាយដល់គាត់វិញ។ តែពេលនេះយើងនិយាយតែពីរយៈកាលមុនឆ្នាំ១៩៧៥សិន។ នៅពេលនោះក្នុងតំបន់២៥ ទំនាស់ខ្លាំងជាងនៅកន្លែងណាផ្សេងទៀតទាំងអស់ "ហើយសភាពការណ៍ច្របូកច្របល់ណាស់ (នន សួន)"។ ដើម្បីដោះស្រាយសភាពការណ៍នេះ វន វេតមានគំរោងដកលេខាតំបន់ចាស់ ដែលជាអ្នកមកពីហាណូយ ឈ្មោះសូពុំចេញ ហើយដាក់នន សួនជំនួសវិញ។ គាត់មាននយោបាយប្រយ័ត្នប្រយែង បន្ថយការប្រឆាំងឲ្យនៅតិចជាអាតិបរិមា ដោយរក្សាទុកសហការីចាស់ របស់សូពុំឲ្យនៅទាំងអស់។ ពេលចាប់ផ្ដើមដំបូងសភាពការណ៍នៅទីនោះតឹងតែង។ នៅឯថ្នាក់ភូមិភាគសូ ភឹមអែអង់ពន្យាពេល។ ដូច្នេះក្នុងរយៈពេលជាងបីខែ តំបន់២៥ស្ថិតនៅក្រោមរដ្ឋអំណាច២ប្រកួតប្រជែងគ្នា។ នន សួន និងសូពុំ មានទីបញ្ជាការរៀងៗខ្លួន ដោយកងទ័ពភាគច្រើននៅក្រោមបញ្ជារបស់សូពុំ។ នៅក្នុងសៀវភៅគាត់ ដែលយើងបាននិយាយដល់ពីខាងលើមកហើយនោះ[២១៦] លោកបែនគៀរណាន់បានស្រង់សេចក្ដីសារភាពរបស់នន សួន ដែលបានរំលឹកពីការណែនាំរបស់វន វេត ដល់គាត់នៅខែកញ្ញា១៩៧១ មុនគាត់ទៅកាន់តំណែងថ្មីរបស់គាត់ ដូចតទៅ គាត់បានប្រាប់ខ្ញុំថា ចម្រើន សុខ និងសី ជាជនក្បត់ដែលបានសម្លាប់យុទ្ធមិត្តម្នាក់ ហើយជាប់ជិតស្និតជាមួយពួកវៀតកុងណាស់ កុំមានវិធានការអ្វីទាំងអស់។ អាចនាំឲ្យប៉ះពាល់ដល់ការខិតខំធ្វើសង្គ្រាម។ ត្រូវខិតខំអូសទាញគេឲ្យមកខាងយើង... ចាំឯករាជ្យ យើងនឹងសម្រេចក្រោយ។ ពេលនេះយើងខំអូសទាញគេឲ្យនៅជាមួយបដិវត្តិន៍ ហើយខិតខំបំពេញ

[២១៦] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ៣៣២



ភារកិច្ចតាមសមត្ថភាពរបស់គេ។ កុំឲ្យវៀតណាមដណ្ដើមគេបាន... នយោបាយដូចគ្នានេះដែរ ត្រូវអនុវត្តចំពោះកម្លាំងទាំងអស់ដែលតាមវៀតណាម ចំពោះគ្រប់ស្រទាប់វណ្ណៈប្រជាជនរហូតដល់លោកសង្ឃ។ កុំឲ្យវៀតណាមដណ្ដើមកម្លាំងទាំងអស់នេះបានប្រឆាំងនឹងអង្គការបដិវត្តិន៍យើង។ វន វេតនិយាយបន្តថា ចំពោះកងទ័ពវៀតណាមនៅតំបន់២៥៖ យើងដោះស្រាយបញ្ហានេះ ដោយបំផុសប្រជាជនឲ្យតស៊ូប្រឆាំងវាវិញតាមគ្រប់មធ្យោបាយ។ ជៀសវាងកុំប្រើអាវុធ បើអាចជៀសបាន។

យើងចង់ហើយយើងត្រូវតែការពារប្រជាជនយើង និងកម្លាំងយោធាយើង។ ត្រូវប្រើនយោបាយជាសំខាន់។ បន្ទាប់មក នន សួនអូសទាញបានគ្រូបង្រៀនមួយចំនួនដែលពីមុនធ្លាប់ធ្វើការជាមួយសូពុំ ដោយរួមមានទាំងសុកផង ដែលគាត់ចាត់តាំងឲ្យធ្វើជាមេបញ្ជាការកងទ័ពរបស់គាត់។ ចំណែកឯគ្រូបង្រៀនប្រហែលជាងដប់នាក់ទៀតនៅស្មោះត្រង់ជាមួយសូពុំនៅឡើយ។ ទោះបីយ៉ាងនេះក៏ដោយ ក៏មិនមានការបាញ់គ្នាទេ ហើយក៏គ្មានការស្លាប់បាត់បង់ជីវិតទេ។ គ្រាន់តែជាជម្លោះនយោបាយ។ ខ្មែរដែលមកពីហាណូយគិតគូរពីក្បួនខ្នាតបច្ចេកទេស និងពីសំភារៈជាសំខាន់ (តាមគំនិតរបស់គេកងអនុសេនាធំត្រូវបំពាក់អាវុធប្រភេទណាៗខ្លះ)។ អ្នកផ្សេងទៀតគិតគូរពីគោលជំហរជាសំខាន់ គឺឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន។ គេមិនទទួលជំនួយពីបរទេសណាទាំងអស់។ នន សួន មិនលើកពីបញ្ហាវៀតណាមទេ ទោះបីអ្នកក្រោមបង្គាប់គាត់លើកក៏ដោយ។ ប៉ុន្តែគាត់យកចិត្តទុកដាក់កសិករជាងសូពុំ។ ចម្រើន និងសី មកជាមួយនន សួន តែនៅតែបន្តរាប់អាន ជិតស្និតជាមួយសូពុំ។ គ្រូបង្រៀនម្នាក់ដែលធ្វើការបានមួយឆ្នាំជាមួយសូពុំ ប៉ុន្តែក្រោយមកជាមួយ នន សួននៅចាំថា៖ "ខ្ញុំបានឃើញគេទាំងពីរនាក់ប្រាស្រ័យទាក់ទងគ្នាល្អ ពេលគេជួបពិភាក្សាគ្នា។ ខ្ញុំបានឮតែអ្នកក្រៅនិយាយថា គេទំនាស់គ្នា ប៉ុន្តែខ្ញុំបានឃើញគេដោះស្រាយបញ្ហាជាមួយគ្នាធម្មតាបំផុត"។ សុកជាបញ្ហាមួយក្នុងបញ្ហារបស់គេនោះ។ គេហាក់ដូចជាស្អប់វៀតណាម

ខ្លាំងណាស់ ហើយគេតែងមានរឿងជាមួយវៀតណាមជាប់ ទោះបីកងទ័ពវៀតណាម និងកងទ័ពខ្មែរទាក់ទងគ្នាបានល្អហើយក៏ដោយ។ កងទ័ពខ្លះរបស់សុកបោះនៅជិតកន្លែងពុំ ហើយនៅពេលមួយនៅឆ្នាំ១៩៧២ សុកត្រៀមរៀបចំវាយពុំ។ ប៉ុន្តែមិនដែលបានវាយទេ។ ពុំជិះម៉ូតូមកជួបនន សួន ហើយជម្លោះក៏ត្រូវបានដោះស្រាយ។[២១៧]

រៀបរាប់រឿងទាំងអស់នេះហើយ លោកបែន គៀរណាន់បន្ថែមទៀតថា យុទ្ធសាស្ត្ររបស់វន វេតប៉ិនប្រសព្វជាងយុទ្ធសាស្ត្រដែលបានអនុវត្តនៅបារាយធ្លាយណាស់។ លោកក៏ឆ្ងល់ប្រឡថា នៅបារាយប៉ុលពតនៅពីក្រោយកែពក ក្នុងការសម្លាប់អ្នកណាដែលគាំទ្រពួកកុម្មុយនីស្តវៀតណាម។ ប៉ុន្តែលោកបែន គៀរណាន់ ក៏ធ្លាប់និយាយពីអត្តចរិតកាចរបស់កែ វិន ហៅ កែពកហើយ តាំងពីពេលដែលគាត់ត្រូវទាហានដេញចាប់គាត់រត់ចូលព្រៃនៅបុសពកកាលពីឆ្នាំ១៩៦២។

ក្រោយមកតាមដែលខ្ញុំបានជួបសន្ទនាជាមួយអតីតកម្មាភិបាល និងអ្នកដែលធ្លាប់ស្គាល់កែពកផ្ទាល់ក្ដីប្រយោលក្ដី គេបញ្ជាក់ថា កែពកដៃក្ដៅអីចឹងមែនតាំងពីគាត់នៅធ្វើតស៊ូរៈម្ល៉េះ។ គាត់ជឿអបិយជំនឿខ្លាំងណាស់។ គាត់ជឿគ្រូអុំ។ នៅប៉ុន្មានឆ្នាំក្រោយឆ្នាំ១៩៧៩ ដែលវៀតណាមចូលឈ្លានពានកម្ពុជា គាត់គិតតែការពារទ្រព្យសម្បត្តិដែលគាត់ប្រមូលបានពេលដែលគាត់កាន់អំណាច ហើយមិនសូវយកចិត្តទុកដាក់គិតគូរគ្រប់គ្រងដឹកនាំកងទ័ពទេ។ តាំងពីពេលនោះមកគាត់ធ្លាក់ចុះរហូត។ នេះគឺជាការបញ្ចាំងនូវសង្គមសក្ដិភូមិនៅជនបទកម្ពុជា ជាសង្គមដែលមានជាន់ មានថ្នាក់ មានមេមានកើយ ដែលមេមានសិទ្ធិអំណាចលើកូន ជាសង្គមដែលពោរពេញទៅដោយអាបធ្មប់ និងអបិយជំនឿសព្វបែបយ៉ាង ដែលពួកអតីតតស៊ូរៈជាទូទៅធ្លាប់រស់នៅពីក្មេងមកផង និងជាកេរ្តិ៍មរតកដែលគេទទួលបានពីពេលដែលគេធ្វើតស៊ូរៈផង។ ខ្ញុំសុំជូនឧទាហរណ៍មួយទៀតដើម្បីបញ្ជាក់ អំពីគោល

[២១៧] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ៣៣២



ជំហររបស់កម្មាភិបាល ដែលធ្លាប់ធ្វើតស៊ូរៈដោយប្រៀបនិងកម្មាភិបាលដែលគោរពតាមមាគ៌ារបស់ដឹកនាំ។ លោកហ្វ្រង់ស្វាប៊ីហ្សូ បានសរសេរអំពីវន វេតបានតស៊ូប្រឆាំងតាម៉ុកដែលមិនព្រមដោះលែងគាត់ ទោះបីប៉ុលពតបានសម្រេចឲ្យដោះលែងហើយក៏ដោយ។ នេះជាឧទាហរណ៍មួយច្បាស់ទៀតអំពីគោលជំហររបស់កម្មាភិបាល ដែលចេញមកពីអតីតចលនាតស៊ូរៈ ផ្ទុយនិងកម្មាភិបាល ដែលគោរពតាមមាគ៌ាដឹកនាំរបស់ប.ក.ក។ ឃើញថា ក្នុងរឿងនេះតាម៉ុកមានគំនិតរបស់គាត់ដោយឡែកច្បាស់។ ហើយតាម៉ុកជាសមាជិកគណៈអចិន្ត្រៃយ៍ផង គាត់ត្រូវយល់ជ្រួតជ្រាបនយោបាយរបស់ប.ក.ក ជាងកែពក ដែលទើបតែបានចូលជាសមាជិកគណៈមជ្ឈិមត្រៀមនៅមហាសន្និបាតឆ្នាំ១៩៧១តែប៉ុណ្ណោះ។ គួររំលឹកផងដែរថា វន វេតបានត្រូវសាឡុតសនាំមកឲ្យធ្វើការជាប់ជាមួយគាត់នៅក្នុងគណៈកម្មាធិការទីក្រុងភ្នំពេញ តាំងពីឆ្នាំ១៩៥៩ ហើយបានត្រូវគាត់ស្នើឲ្យឡើងមកដឹកនាំគណៈកម្មាធិការនេះមុននឹងគាត់ចាកចេញពីភ្នំពេញទៅចូលព្រៃនៅឆ្នាំ១៩៦៣។ រយៈកាលនោះជារយៈកាលមួយសំខាន់ដែរក្នុងប្រវត្តិរូបនយោបាយរបស់វន វេត។ អាចនិយាយម្យ៉ាងទៀតថា ការខិតខំរៀបចំបក្សមួយឲ្យឯកភាពគ្នាជាធ្លុងមួយ ជាការលំបាកណាស់ ពិសេស ប.ក.ក ដែលមាននិន្នាការពីរផ្សេងគ្នាតាំងពីដើមទីមកស្រាប់ទៀត។ ឧទាហរណ៍ដូចជាតាម៉ុកបានឯកភាពច្រើនណាស់ហើយ តែក៏នៅមានចំណុចមួយចំនួនទៀតមិនទាន់ឯកភាព។ តើត្រូវធ្វើម៉េច? ត្រូវបោះបង់ចោលឬត្រូវលើកទឹកចិត្តហើយខំកសាងតទៅទៀត? ប៉ុលពតយល់ឃើញថា ខំកសាងតទៅទៀត ពីព្រោះកម្មាភិបាលនីមួយៗមានតម្លៃណាស់ មិនងាយកសាងបានទេ។

### ង-លោកបែនគៀរណាន់បានអះអាងថា ការិយាល័យនយោបាយបានត្រូវរំលងជាញឹកញយ

ហើយក្រុមមួយទៀតដែលមានគ្នាតិចជាងនេះ បានយកសេចក្ដីសម្រេចជំនួស។[២១៨]

[២១៨] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ៣១១

ការពិតចលនាណាក៏ដោយ បើមិនគោរពតាមលក្ខន្តិកៈសោះទេ មិនអាចរីកលូតលាស់បានទេ។ ក្នុងករណីដែលលោកបែន គៀរណាន់បានលើកនេះ អាចជាការអនុវត្តគោលការណ៍មួយដែលមានចែងក្នុងលក្ខន្តិក ប.ក.ក ក៏ដូចជាក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តផ្សេងទៀតទាំងអស់ហៅថា ប្រជាធិបតេយ្យប្រមូលផ្ដុំ ដែលជាគោលការណ៍មួយសំខាន់នៃការចាត់តាំងដឹកនាំរបស់គេ។ តាមទ្រឹស្ដីគោលការណ៍នេះ ចេញមកពីជាតុវណ្ណៈរបស់បក្សគេដែលគេកំណត់ថា ជាបក្សរបស់វណ្ណៈពលករ ត្រូវមានគោលការណ៍នេះ ដើម្បីកុំឲ្យអ្នកមកពីវណ្ណៈផ្សេងទៀតបន្ទំចូលបាន។ ក្នុងការជាក់ស្ដែងគោលការណ៍នេះចេញមកពីសេចក្ដីត្រូវការនៃការតស៊ូសម្ងាត់ និងការលំបាកនៃការទាក់ទង។ គោលការណ៍នេះបើកសិទ្ធិឲ្យគណៈកម្មាធិការអចិន្ត្រៃយ៍ ឬលេខាបក្សមានសិទ្ធទូលំទូលាយធ្វើសេចក្ដីសម្រេចបាន តែមិនអាចសម្រេចអ្វីដែលផ្ទុយពីមាគ៌ាដែលបានកំណត់មកហើយក្នុងមហាសន្និបាតមុន ឬសេចក្ដីសម្រេចចិត្តមុនរបស់គណៈកម្មាធិការមជ្ឈឹមទេ។ ក្នុងចលនារបស់ ប.ក.ក ឥទ្ធិពលដឹកនាំរបស់ប៉ុលពតនៅក្នុងបក្ស បានកើនឡើងជាលំដាប់ពីសេសពីឆ្នាំ១៩៦៨-៦៩ រហូតដល់ឆ្នាំ១៩៧៥។ គាត់បានក្លាយទៅជា "អ្នកដឹកនាំជាប្រវត្តិសាស្ត្រមួយរូបដែលសម្រេចមិនចេះខុស"។

### ច-បញ្ហាល្អិតមួយចំនួនទៀត

-ហេតុម្ដេចក៏សន្និបាតឆ្នាំ១៩៧១ ដែលបានធ្វើក្នុងតំបន់រំដោះដ៏ទូលំទូលាយហើយនោះ នៅតែបន្តប្រជុំដោយកំបាំងពីសមាជិកបក្សទូទៅទៀត? នេះក៏ជាបញ្ហាដែលគួរជម្រាបដែរ។ មូលហេតុគឺមកពីសភាពការណ៍ស្មុគស្មាញមហាស្មុគស្មាញ ៖

ទី១-ប.ក.ក.ចេញចំហមិនទាន់បានទេ។ បើចេញនាំឲ្យបាក់បែករណសិរ្សជាមួយសម្ដេចព្រះនរោត្តម សីហនុ។ ដូច្នេះខាតដល់ការតស៊ូរំដោះជាតិ។

ទី២- បញ្ហាដែលត្រូវពិភាក្សាគ្នានៅពេលនោះដូចជាបញ្ហាត្រូវកំណត់ថា វៀតណាមជាអ្វី? ជាដើមហើយដែលជាបញ្ហាសំខាន់កំណត់មាគ៌ាចំពោះវៀតណាម ក៏ពុំអាចធ្វើទៅបានជាចំហដែរ។



ជាទូទៅតាំងពីកំណើតរបស់ ប.ក.ក នៅឆ្នាំ១៩៦០ ក្នុងឋានៈជាបក្សមួយឯករាជមកអ្វីៗក៏ត្រូវធ្វើដោយសម្ងាត់ពី "វៀតណាមជាវៀមច្បង" ទាំងអស់។ នេះហើយដែលមួយផ្នែកធំនាំឲ្យរបៀបរបបធ្វើការរបស់ ប.ក.ក ខុសផ្លែកពីបក្សកុម្មុយនីស្តផ្សេងទៀតក្នុងសាកលលោក។ ស្អីក៏ស្ងាត់ៗ។

-ហេតុម្ដេចបានជា ត្រូវបំផុសប្រជាជនឲ្យតស៊ូប្រឆាំងវៀតណាម តាមគ្រប់មធ្យោបាយដូចដែលវ៉ន វេត បានណែនាំនន សួននោះ? នេះគឺមកពីវៀតណាមជាមិត្តមានទំនាស់ មានបំណងចង់ ហើយបានប្រព្រឹត្តអំពើជាច្រើនណាស់មក ហើយប៉ុនប៉ងគ្រប់គ្រងកម្ពុជា។ ដូច្នេះត្រូវតែតស៊ូវិញតាមគ្រប់មធ្យោបាយ។ តែត្រូវជៀសវាងកុំប្រើអាវុធ បើអាចជៀសបាន។

### ២. អំពីសភាពការណ៍ឬព្រឹត្តិការណ៍មួយចំនួនដែលអ្នកស្រាវជ្រាវ មិនបាននឹកឃើញដល់

គេបានចោទប្រកាន់ទៅលើប៉ុលពតអំពីថា បានជម្លៀសប្រជាជនចេញពីទីក្រុង និងពីទីរួមខេត្ត។ តែក្នុងការចោទប្រកាន់នេះ គេមិនបាននឹកដល់សភាពការណ៍ដ៏លំបាកមហាលំបាក និងពោរពេញទៅដោយហិង្សាដែលរដ្ឋអំណាចដ៏ក្មេងខ្ចីត្រូវប្រឈមមុខនោះទេ។ គេភ្លេចថា ជនបទមួយផ្នែកធំត្រូវបានខ្ទេចខ្ទាំដោយការទម្លាក់គ្រាប់បែក ឬត្រូវបោះបង់ចោល។ ភ្នំពេញត្រូវគំរាមកំហែងដោយគ្រោះអាសន្នអត់បាយដាច់ពោះ តាំងពីមួយឆ្នាំមុនថ្ងៃ១៧ មេសា១៩៧៥ម្ល៉េះ។ សភាពការណ៍ពិត គឺដូចយើងបានដកស្រង់លោកហ្សូវគ្រូស និងលោក មិកាអែល វីឃើរី។

ដែលអាចនាំឲ្យមានគ្រោះថ្នាក់ធំដល់រដ្ឋអំណាចដ៏ក្មេងខ្ចី គឺសភាពការណ៍ដែលមនុស្សរាប់ម៉ឺននាក់បានស្លាប់រួចមកហើយ ហើយមានអ្នកដែលកំពង់តែផ្ដេតៗចាំតែស្លាប់បន្តគ្នាយ៉ាងនេះ ជាលក្ខណៈអនុគ្រោះណាស់ឲ្យភ្នាក់ងារសេអ៊ីអាចធ្វើវិទ្ធង្សនា ហើយរួមជាមួយសំណល់នៃកងទ័ពលន់ នល់ ដែលច្បាស់ជានៅមានលាក់អាវុធនៅក្នុងទីក្រុង និងគ្រប់កន្លែង

ទូទាំងប្រទេស និងបង្កើតឲ្យមានការបះបោរនៅភ្នំពេញ និងនៅកន្លែងផ្សេងៗទៀតនៅក្នុងប្រទេស។ គ្រោះថ្នាក់ធំជាងគេបំផុត គឺការបះបោរ និងចលាចលទាំងនោះ និងបង្កជាឱកាសឲ្យវៀតណាមងាយស្រួលធ្វើអន្តរាគមន៍ពីក្រៅដណ្តើមយកកម្ពុជាពីអាមេរិកវិញ ដោយយកលេសថា មកជួយសង្គ្រោះ។ ពេលនោះក្នុងការជាក់ស្តែងទោះបីចង់ ឬមិនចង់ ក៏ដោយគឺសេអ៊ីអា និងពួកកុម្មុយនីស្តវៀតណាមទៅជារួមគ្នាសម្ងាប់រដ្ឋអំណាចថ្មីហើយ។ សភាពការណ៍នេះហើយដែលមេៗខ្មែរក្រហមបារម្ភជាងគេបំផុត។

តើទីភ្នាក់ងារសេអ៊ីអា មានមែនឬមិនមាននៅភ្នំពេញពេលនោះ? មន្ត្រីផ្លូវការសេអ៊ីអា ដោយរួមទាំងមេធំនៅព្រៃនគរឈ្មោះហ្រ្វាំងស្នីពផង[២១៩] បានញ្ជាក់ច្បាស់ថា គេបានរក្សាទុកខ្សែទាក់ទងតាមវិទ្យុ និងបណ្តាញសាខាសម្ងាត់របស់គេនៅកម្ពុជាអីចឹងមែន តែបណ្តាញទាំងអស់របស់គេត្រូវខ្ចាត់ខ្ចាយអស់ដោយសារតែការជម្លៀសប្រជជនចេញពីទីក្រុង។

អ្នកនិពន្ធខ្លះសង្ស័យថា ប៉ុលពតបានបំផ្លើសអំពីគ្រោះអាសន្នវៀតណាមដើម្បីបានជាលេសអនុវត្តមនោគមវិជ្ជាជ្រុលហួសរបស់គាត់។ ពិតមែនហើយលោកប៉ុលពត មិនបានឃើញភស្តុតាងច្បាស់ពីវៀតណាមបង្កើតចលនាខ្មែររំដោះនោះទេ ប៉ុន្តែក៏គាត់បានឃើញ"កងទ័ពរំដោះ" នេះរួមជាមួយវៀតណាមវ៉ៃកងទ័ពរបស់គាត់ និង ម្យ៉ាងទៀតគាត់ដឹងខ្លួនច្បាស់ថាវៀតណាមមិនពេញចិត្តនឹងនយោបាយឯករាជ្យរបស់គាត់ទេ។ គ្រាន់តែមកដល់ពេលនេះគេធ្វើអ្វីគាត់ពុំទាន់បានប៉ុណ្ណោះ។ ទីចុងបំផុតឱសានិវាទរបស់វៀតណាមខែឧសភាឆ្នាំ១៩៧៦ ដូចយើងបានពិនិត្យពីខាងលើមកហើយនេះ បញ្ជាក់ច្បាស់ថាការព្រួយបារម្ភរបស់ប៉ុល ពត មានមូលដ្ឋានជាក់ស្តែងពិតប្រាកដមែន។ ហើយគាត់ឃើញច្បាស់ថាត្រូវរត់ឲ្យលឿនទៀត។ នេះមកពីគាត់បានទៅជួបជជែកជាមួយឡេ យន់ដោយផ្ទាល់៣លើក មួយលើកៗសុទ្ធតែមានទំនាស់

[២១៩] វីលីយ៉ាំ ហ្សូវក្រូស "ទុក្ខសោកវេទនាមួយដែលគ្មាននរណាគិតគូរដល់" ទំព័រ៣៥២



តឹងតែងណាស់។ គាត់ថែមទាំងបានអានឯកសារវៀតណាមល្អិតល្អន់ទៀត។ យើងនៅចាំបានហើយ ក្រោយពីបានអានឯកសារវៀតណាមកាលពីឆ្នាំ១៩៦៥ គាត់ថាម្តេច? គាត់ថា ៖ "...ក្រោយពីបានអានឯកសារទាំងអស់នោះទៅ ខ្ញុំឈប់ជឿលើគេហើយ។ ខ្ញុំឃើញថា គេបានចាត់តាំងអង្គការបក្សនៅក្នុងស្រុកយើង ដើម្បីសម្រេចទិសដៅយុទ្ធសាស្ត្រតែមួយ គឺសហព័ន្ធឥណ្ឌូចិន។ គេបានបង្កើតបក្សតែមួយដើម្បីគ្រប់គ្រងឲ្យទឹកដីដែលបញ្ចូលគ្នាតែមួយ...។"

ហើយគាត់មិននិយាយតែមាត់ទទេទេ។ ក្រោយពីបានជួបលើកទី១នេះត្រឡប់មកវិញគាត់ដូរឈ្មោះបក្ស ដើម្បីបញ្ជាក់ថា តាំងពីថ្ងៃនេះទៅបក្សខ្មែរឯករាជពីវៀតណាមហើយ ហើយណែនាំឲ្យភូមិភាគនីមួយៗត្រៀមរៀបចំឈានទៅមុខមួយជំហានទៀត។ គឺត្រៀមរៀបចំតស៊ូអាវុធទោះបីឡេ យន់ថាម៉េចក៏ដោយ។ ខំប៉ុណ្ណឹងហើយនៅតែចង់យឺតជាងសភាពការណ៍ទៀត។ លោកលន់ នល់នៅកាត់កប្រជាជនកសិករនៅសំឡូត និងនៅកន្លែងផ្សេងទៀតអស់រាប់រយនាក់ទៀតទើបរៀបចំការតស៊ូអាវុធបាន។ ពេលមានចលនាតស៊ូអាវុធហើយ ទើបវៀតណាមដឹងថា ប៉ុលពតមិនព្រមរណបគេទេ។ ឯអ្នកស្រាវជ្រាវជាទូទៅ នៅតែមើលមិនឃើញគោលជំហរឯករាជ្យនេះរបស់ប.ក.កហើយក៏មិនឃើញទំនាស់ ជាមួយពួកកុម្មុយនីស្តវៀតណាមយ៉ាងដូចម្តេចនោះដែរ។ គេមើលទៅថា ការតស៊ូអាវុធនេះរប៉េះរប៉ោះ មិនមានន័យអ្វីធំដុំទេ។ តើវាធ្វើឲ្យសភាពការណ៍នៅកម្ពុជាប្រែប្រួលយ៉ាងណា ក៏គេមិនដឹង ធ្វើឲ្យពួកកុម្មុយនីស្តវៀតណាមទំនាស់ជាមួយបក្សខ្មែរយ៉ាងណា ក៏គេមិនដឹង។ វៀតណាមចោទប៉ុលពតថា មិនព្រមស្តាប់គេ ហើយតស៊ូអាវុធធ្វើឲ្យសម្តេចនរោត្តម សីហនុលំបាក បែរទៅសំរូលជាមួយសហរដ្ឋអាមេរិកបើកដៃឲ្យសហរដ្ឋអាមេរិកចូលទៅវាយគេនៅរតនៈគីរី និងមណ្ឌលគិរី ហើយទំលាក់គ្រាប់បែកបេ៥២លើជម្រករបស់គេតាមប្រតិបត្តិការ "មីនុយ"។ ថែមទាំងសម្តេចទៅព្រមានគេទៀត។ ក្រោយមកនៅចុងឆ្នាំ១៩៦៩ ពេលប៉ុលពតទៅទស្សនកិច្ចនៅហាណូយជាលើកទី២ ឡេ យន់ខឹងនឹងប៉ុលពតប្រឡោតតោតតូង យ៉ាង

ណាបង្កើតជាបរិយាកាសនាំឲ្យលោកស្រីខៀវ ប៉ុណ្ណារីរង្គោះរង្គើយ៉ាងណាក៏គេមិនដឹង។

ក្រោយរដ្ឋប្រហារ និងក្រោយពីកើតមានសម្ព័ន្ធភាពរវាងសម្តេចនរោត្តមសីហនុជាមួយខ្មែរក្រហមបរិយាកាសក៏ប្រែប្រួលមកឱបរឹតគ្នាវិញ។ ប៉ុលពតប្រើពាក្យថា ប្រែ១៨០អង្សា។ មានតែពាក្យ "មិត្តភាព" "សាមគ្គីភាពដូចបងប្អូនបង្កើតមិនដាច់ពីមាត់ទេ។ ប៉ុន្តែបានតែមួយភ្លែតតែប៉ុណ្ណោះ។ ដល់ពេលប៉ុលពតប្រកែកមិនព្រមទទួលយល់ស្របតាមការស្នើចាត់តាំង បញ្ហាការចម្រូះទំនាស់ក៏កើតឡើងវិញ។ តែលើកនេះមិនចេញជាបាតុភាពអ្វីនៅខាងក្រៅទេ។ អ្នកស្រាវជ្រាវរិតតែពិបាកឃើញទៀត។ ហើយទំនាស់ និងការប៉ះទង្គិចចេះតែមានជាបន្តបន្ទាប់មកទៀត។ ពេលដែលប៉ុលពត ទៅដល់ប្រទេសគាត់ ស្រាប់តែឃើញកងទ័ពវៀតណាមពាសពេញកម្ពុជាទៅហើយ។ វៀតណាមថា ទោះជាកម្ពុជាយល់ស្រប ឬមិនយល់ស្របក៏ដោយ គេត្រូវតែចូលហើយ។ ត្រង់នេះអ្នកស្រាវជ្រាវជាទូទៅក៏មិនដឹង។ បែន គៀរណាន់ដឹង តែក៏គាត់មិនបានយកចិត្តទុកដាក់ពិនិត្យទេថា តើសំដីរបៀបនេះ អំពើរបៀបនេះរបស់ពួកកុម្មុយនីស្តវៀតណាម ប៉ះពាល់យ៉ាងណាដល់ទឹកចិត្តរបស់ប៉ុលពតដែលគាត់បានខំរាប់សិបឆ្នាំមកហើយ ដើម្បីកិត្តយស់ជាតិរបស់គាត់នោះទេ។

ចូលមកហើយ ក៏ដៃគេលូកចូលកក្កូរផ្ទៃក្នុងទៀត គេបង្កើតរដ្ឋអំណាចពីរ។ បញ្ហានេះតស៊ូជាមួយគ្នារាប់ឆ្នាំ ទើបដោះស្រាយបាន។ រួចមកនៅបូព៌ាគេធ្លៀតឱកាសពង្រឹងពង្រីកឥទ្ធិពលរបស់គេ នៅពេលដែលគេបានចូលមកហ៊ឹកហ៊ឺនកម្មាភិបាលគ្រប់ផ្នែកដោយរួមទាំងកម្មាភិបាលយោធាផង។ គេណែនាំឲ្យកងទ័ពបូព៌ាក្លែងខ្លួនធ្វើជា "កងទ័ពរំដោះ" "លំអៀងខាងសម្តេចសីហនុ" "លំអៀងខាងវៀតណាម" រហូតដល់មានរឿងធ្វូងទន្ទេមេគង្គចូលភូមិភាគនីមួយៗ វាយគ្នាទៅវិញទៅមក រហូតដល់ពេលរំដោះទូទាំងប្រទេស។ ទាំងអស់នេះ ក៏អ្នកស្រាវជ្រាវមើលមិនឃើញបាតដៃរបស់វៀតណាម។



ម៉្យាងពេលនោះភាគីទាំងពីរ ទាំងខាងកម្ពុជា ទាំងខាងវៀតណាម បិតបាំងរឿងទាំងអស់នេះ។ ក្រោយមកខាងវៀតណាមផ្សាយតែឯកសារណាដែលចំណេញដល់គេ។ នេះហើយដែលនាំឲ្យមានការលំបាកដល់អ្នកស្រាវជ្រាវដើម្បីដឹងរឿងឲ្យបានគ្រប់ជ្រុងជ្រោយ។ ម៉្យាងទៀតក្នុងរឿងទាំងអស់នេះអាចមានកត្តាអត្តនោម័ត ស្រឡាញ់ស្អប់ចូលលាយឡំផងដែរ ជួនណាដោយអ្នកស្រាវជ្រាវមិនដឹងខ្លួនផងក៏មាន។ ជាទូទៅគេស្អប់ប៉ុលពតដោយសារនយោបាយ "ជ្រុលហួស" របស់គាត់ ដូច្នេះចង់ឬមិនចង់មានលំអៀងហើយ។ គេភ្លេចរកមើលមូលហេតុអ្វីដែលនាំឲ្យប៉ុលពត មាននយោបាយជ្រុលហួសយ៉ាងនេះ។ គេភ្លេចរឿងទម្លាក់គ្រាប់បែកបេ៥២ទៅលើកម្ពុជា ដោយសារតែកម្ពុជាមិនព្រមរណបគេនិងវៀតណាម។ វៀតណាមរំលោភបំពាន ឬលូកដៃចូលមកកក្កូរផ្ទៃក្នុងកម្ពុជាយ៉ាងណាក៏គេមិនឈឺចាប់ ដូចខ្មែរដែលបានខិតខំតស៊ូលំបាកវេទនាជាបន្តបន្ទាប់មកនោះទេ។ សូម្បីតែកម្មាភិបាលបក្សមួយចំនួនច្រើនក៏មិនដឹងរឿងតើវៀតណាមរំលោភលើខ្មែរអស់ដែរ។ ចំពោះប៉ុលពតវិញ រឿងដូចបានសរុបឡើងវិញទាំងអស់ខាងលើនេះ សុទ្ធតែបានបញ្ជាក់សេចក្តីសន្និដ្ឋានរបស់គាត់តាំងពីឆ្នាំ១៩៦៥មកគឺថា "គេបានបង្កើតបក្សតែមួយ ដើម្បីគ្រប់គ្រងទឹកដីដែលបញ្ចូលគ្នាតែមួយ។" ឥឡូវគាត់បានបង្កើតបក្សកុម្មុយនីស្តកម្ពុជាមួយឯករាជពីពួកកុម្មុយនីស្តវៀតណាម ដែលវៀតណាមចោទថា "ប្រតិកិរិយា" "ជាតិនិយមចង្អៀតចង្អល់" "បរិវារចិន"។ វៀតណាមអត់ឱនឲ្យមិនបានទេ។ សហភាពសូវៀតក៏យល់ថា នេះជាការរំលោភបំពានលើគោលការណ៍ "អន្តរជាតិនិយមវណ្ណៈអធន" ធ្ងន់ធ្ងរណាស់។ នៅអឺរ៉ុបខាងកើត គេធ្លាប់ផ្តន្ទាទោសអំពើរំលោភបែបនេះ យ៉ាងណាក៏អ្នកផងធ្លាប់ដឹងឮអស់ហើយ។ តែនៅពេលនេះ វៀតណាមនៅត្រូវការទឹកដីកម្ពុជាជាបង្អែកខាងក្រោយនៅឡើយ គេក៏អត់ធ្មត់សិន។ ចាំដល់ពេលគេរំដោះហើយ គេបង្រួបបង្រួមប្រទេសបានហើយ ចាំគេបែរមកគិតគូរដោះស្រាយបញ្ចប់ប៉ុលពត។ នេះហើយជាឬសគល់នៃឱសានុវាទខែឧសភា ១៩៧៦។ នេះហើយដែលប៉ុលពតគាត់ដឹង

ខ្លួនមុនៗ ដូច្នេះហើយបានជាគាត់ថា កម្ពុជាចាំបាច់ត្រៀមរៀបចំខ្លួនឲ្យរហ័ស ដើម្បីប្រឈមមុខទល់ និងការគំរាមកំហែងពីហាណូយៗ ដូច្នេះហើយបានជាគាត់តែងទន្ទិញថា "យើងត្រូវរត់ឲ្យលឿនដើម្បីកុំឲ្យយួនដេញក្រញែចយើងទាន់"ៗ ក្នុងសង្គ្រាម រត់បានលឿនហើយ ដោយរំដោះភ្នំពេញបានមុនវៀតណាម១៥ថ្ងៃៗ បើវៀតណាមរំដោះភាគខាងត្បូង ហើយភ្នំពេញនៅមិនទាន់បានរំដោះនោះអាចមានគ្រោះថ្នាក់ធំហើយៗ រត់បានផុតម្តងហើយ ក្រោយរំដោះក៏ត្រូវរត់ទៀតៗ មិនអាចអែអង់បានទេៗ នេះហើយបានជាប៉ុលពតសម្លឹងមើលទៅឃើញថា ការពង្រីកសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេសធ្វើឲ្យ "បដិវត្តន៍នៅកម្ពុជាបានលឿនជាងបដិវត្តន៍នៅចិន កូរ៉េ (ខាងជើង) និងនៅវៀតណាម៣០ឆ្នាំ"ៗ គាត់មានជំនឿលើសហករណ៍ណាស់ ពីព្រោះដោយសារតែមានការចាត់តាំងសហករណ៍តាំងពីដើមឆ្នាំ១៩៧១ទៅហើយ ទើប ប.ក.ក ក្តាប់ស្រូវបាន ក្តាប់សេដ្ឋកិច្ចបាន ក្តាប់មនុស្សបាន ចរចាជាមួយពួកកុម្មុយនីស្តវៀតណាមទាមទារឲ្យគេប្រគល់កងទ័ព និងរដ្ឋអំណាចដែលគេបានចាត់តាំងទាំងប៉ុន្មានឲ្យមកខ្មែរវិញបាន ហើយសុខចិត្តដឹកជញ្ជូនគ្រាប់រំសេវជាជំនួយចិនមកឲ្យខ្មែរ ហើយគោរពអធិបតេយ្យភាពខ្មែរៗ បើគ្មានការចាត់តាំងសហករណ៍ទេ កម្ពុជានឹងត្រូវទទួលបច្ច័យនៃសភាពការណ៍ទាំងអស់ ដែលកើតមាននៅវៀតណាម ក្នុងនេះរួមទាំងការគោរពកិច្ចព្រមព្រៀងប៉ារីសឆ្នាំ១៩៧៣ រវាងវៀតណាម និងអាមេរិកផងៗ ដល់ចុងឆ្នាំ១៩៧២ ដើមឆ្នាំ១៩៧៣ ដោយសារតែមានការតម្លើងថ្នាក់សហករណ៍ ដែលចាត់តាំងពីមុនមកឲ្យទៅជាសហករណ៍កម្រិតខ្ពស់ ហើយបានពួកខ្មែរក្រហមបន្តការតស៊ូដោយឯករាជ្យបានៗ សហករណ៍កម្រិតខ្ពស់ទាំងនោះ បានក្លាយទៅជាឧបករណ៍រដ្ឋអំណាចមួយដ៏មានប្រសិទ្ធភាពដើម្បីប.ក.ក ក្តាប់កម្លាំងទាំងអស់ ទាំងកម្លាំងសេដ្ឋកិច្ច ទាំងកម្លាំងមនុស្ស ទាំងកម្លាំងនយោបាយ ទាំងកម្លាំងមនោគមវិជ្ជាដើម្បីឈ្នះសង្គ្រាម ដើម្បីប្រទេសកម្ពុជាដ៏តូចមួយអាចធ្វើការតស៊ូដណ្តើមយកឯករាជ្យ បានពីមហាអំណាចទាំងធំ ទាំងមធ្យម ហើយរក្សា



ឯករាជ្យបានៗ តួនាទីជាយុទ្ធសាស្ត្រនៃការរៀបចំជនបទជាសហករណ៍ក្នុងសង្គ្រាម៥ឆ្នាំនេះ អ្នកស្រាវជ្រាវមិនសូវបានមើលឃើញទេៗ ឥឡូវនេះ បើចង់ដោះស្រាយឲ្យបានបាយហូបឆាប់រហ័ស បើចង់ឲ្យកម្ពុជាចេញផុតពីភាពក្រីក្រ បើចង់បានឲ្យកសិកម្ម កម្ពុជាបានទៅជាទំនើប បើចង់បោះមូលដ្ឋានដើម្បីកម្ពុជាអាចឈានទៅមានឧស្សាហកម្មជាជំហានៗ បើចង់រត់ឲ្យបានលឿនកុំឲ្យវៀតណាមដេញក្រញិចទាន់ ក៏លោកប៉ុលពតសម្លឹងមើលទៅឃើញតួនាទីសំខាន់នៃសហករណ៍ទៀតៗ លោកប៉ុលពត ឃើញថា តាមរយៈសហករណ៍ពិសេសតាមរយៈសហករណ៍កម្រិតខ្ពស ដីធ្លីទូទាំងប្រទេស និង ទៅជាកម្មសិទ្ធិរបស់ប្រជាជនៗ ដូច្នេះប.ក.ក អាចដឹកនាំប្រជាជនធ្វើទំនុប ជីកប្រឡាយបានខ្វាត់ខ្វែងពាសពេញជនបទ ដើម្បីដោះស្រាយបញ្ហាទឹកស្រោចស្រពស្រែបានខ្ទបប្រាំងខួបវស្សាៗ នេះហើយបានជាលោកប៉ុលពត ថាការពង្រីកសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស ធ្វើឲ្យ "បដិវត្តន៍នៅកម្ពុជាបានលឿនជាងបដិវត្តន៍នៅចិន កូរ៉េ (ខាងជើង) និង នៅវៀតណាម៣០ឆ្នាំ"ៗ ដូច្នេះបើនិយាយម្យ៉ាងទៀត ដើម្បីបានទំនប់ប្រឡាយ ស្រោចស្រប់ជនបទកម្ពុជាខ្វាត់ខ្វែងពាសពេញប្រទេស បើចង់ដោះស្រាយឲ្យបានបាយហូបគ្រប់គ្រាន់បានឆាប់ បើចង់ឲ្យកម្ពុជាចេញផុតពីភាពក្រីក្រ បើចង់បានឲ្យកសិកម្មកម្ពុជាបានទៅជាទំនើប បើចង់បោះមូលដ្ឋានដើម្បីកម្ពុជាអាចឈានទៅមានឧស្សាហកម្មជាជំហានៗ លុះត្រាតែធ្វើបដិវត្តន៍សង្គមនិយម លុះត្រាតែម្នាក់ៗនៅក្នុងការចាត់តាំង ហើយទាំងអស់គ្នាខំប្រយុទ្ធកម្ចាត់បុគ្គលសួនតួ ហើយខំបំពាក់ឲ្យខ្លួនឯង និងអង្គភាពរបស់ខ្លួននូវ "គោលជំហរសមូហភាព" ដើម្បីទាំងអស់គ្នាស្មោះត្រង់ និងគ្នាទៅវិញទៅមក ក្នុងឋានៈជាសមាជិកសហករណ៍ ហើយស្រុះកម្លាំងគ្នាធ្វើការងាររីករាយ ក្នុងការងារមិនចាំបាច់មានអ្នកណាបង្ខំៗ តែដើម្បីបានដល់ទិសដៅនោះ ដោយប្រទេសទើបចេញពីសង្គ្រាមហិនហោច មហាហិនហោច ហើយកំពុងប្រឈមមុខនឹងគ្រោះអាសន្នអត់បាយដាច់ពោះស្លាប់ ចាប់ផ្តើមដំបូងត្រូវជម្នះសភាពការណ៍ដ៏លំបាក មហាលំបាក

ដែលរដ្ឋអំណាចដ៏ក្មេងខ្ចីត្រូវប្រឈមមុខនេះសិន។ ដូច្នេះត្រូវមានការបង្ខំសិនហើយ។ គឺបង្ខំឲ្យធ្វើការទៀយហត់ក្នុងសភាពខ្វះសព្វខ្វះគ្រប់ ទាំងអ្នកធ្លាប់ ទាំងអ្នកមិនធ្លាប់។ ពីព្រោះពេលវេលាបន្ទាន់ណាស់។ ដល់មានហូបចុកគ្រប់គ្រាន់គ្រប់ៗគ្នាទៅ ឃើញវាលស្រែ ដ៏ល្វឹងល្វើយជាក្រឡាឈើត្រង់ទៅជាបណ្ដើរៗទាំងអស់គ្នា កាន់តែពេញចិត្ត និងការដែលខ្លួនបានចូលរួមកសាងប្រទេសដោយដៃរបស់ខ្លួន ទើបទាំងអស់គ្នាកាន់តែពេញចិត្តពេញថ្លើមចំពោះខ្លួនឯងទាំងអស់គ្នាកាន់តែជ្រះស្រឡះហើយ។ តែនេះជាមាគ៌ារួមទេ។ តែត្រូវមានកម្មាភិបាលមូលដ្ឋាន ដែលជ្រួតជ្រាបមាគ៌ា ហើយយកមាគ៌ាទៅអនុវត្តដោយចេះបត់បែនឲ្យបានរស់រវើកតាមការជាក់ស្ដែងទៀត តាមអ្នកឈឺ អ្នកជាតាមកម្លាំងរបស់ម្នាក់ៗ។ មិនមែនចេះតែបង្ខំៗទាំងកម្រោល ហើយមិនពន្យល់ហេតុផលអ្វីសោះដល់គេនោះទេ។ បញ្ហាពន្យល់ហេតុផលដល់មហាជននេះហើយដែលជាការលំបាក។ តាមខ្ញុំយល់ ប.ក.ក មិនសូវមានកម្មាភិបាលដែលចេះពន្យល់មហាជនឲ្យបានជ្រៅជ្រះទេ។ វគ្គរៀនសូត្រដើម្បីកសាងពីរឿងនេះមានច្រើនណាស់ តែតាមខ្ញុំយល់គេមិនសូវចាប់បានខ្លឹមសារប៉ុន្មានទេ។ បានជាខ្ញុំហាននិយាយ ដូច្នេះពីព្រោះនៅឆ្នាំ ១៩៩៩-២០០០ ខ្ញុំដើររកយល់ជីវភាពប្រជាជនយើងតាមភូមិមួយចំនួន ក្នុងមូលដ្ឋានចាស់របស់ខ្មែរក្រហមពីមុន ខ្ញុំឃើញថា ភូមិនីមួយៗមិនមានការប្រែប្រួលអ្វីខុសពីភូមិដែលខ្ញុំធ្លាប់ឃើញនៅជនបទយើងកាលពីមុន ខ្ញុំចេញពីភ្នំពេញទៅកាលពីឆ្នាំ១៩៦៧ទេ។ គឺប្តីប្រពន្ធនៅជេរស្ដីគ្នាប្រាស់ផ្ទះ ប្ដីក៏ផឹកស្រា ប្រពន្ធក៏លេងបៀរ។ ដូច្នេះឈ្លោះគ្នាជាប់ វៃចានវៃឆ្នាំង ធាក់ជញ្ជាំងផ្ទះ កាប់ចិញ្ច្រាំ ឬ ដុតអ្វីដែលមានបន្តិចបន្តួចចោលខ្ទេចខ្ទីអស់ហើយ។ បាត់ស្រវឹងទៅទើបនាំគ្នាប្រមែប្រមូលសាជាថ្មីឡើងវិញ។ ឯការដាំបន្លែបង្ការជុំវិញផ្ទះដើម្បីរួមផ្សំកែប្រែជីវភាព ក៏មិនសូវឃើញមានទេ។ តាមរយៈនេះខ្ញុំសន្និដ្ឋានថាកម្មាភិបាល ប.ក.ក ជាទូទៅមិនចេះធ្វើការងារប្រជាជនទេ មិនចេះរៀបចំសង្គមមិនចេះគ្រប់គ្រងមហាជននៅតាមភូមិ ឃុំ ឬ តាមសហករណ៍ទេ។ ធ្វើការងារប្រជាជនត្រូវដាក់



ខ្លួនឲ្យទាប។ បើនិយាយតាមភាសាដែលគេធ្លាប់ប្រើក្នុង ប.ក.ក ពីមុន គឺត្រូវជាប់មហាជន មានមាគ៌ាមហាជន ហើយចេះពាំនាំមាគ៌ានយោបាយរួមទៅផ្សព្វផ្សាយឲ្យជ្រួតជ្រាបដល់មហាជន។ គេពូកែខាងច្បាំង។ ច្បាំងទាមទារសេចក្ដីក្លាហាន។ គេចេះតែប្រមូលកងទ័ព តាមរបៀបឥស្សរៈ។

ក្នុងផែនការកសាងសេដ្ឋកិច្ច ខ្ញុំបានឃើញមានការណែនាំដូចតទៅ។ "បើពីនេះទៅ១៥ឆ្នាំទៀត យើងសម្រេចទិសដៅរបស់យើងនេះមិនបានទេ គឺមិនមែនមកពីកត្តាខាងក្រៅទេ គឺមកពីកត្តាខាងក្នុង មានន័យថា មកពីការដឹកនាំរបស់បក្ស។ ដោយឈរលើគោលការណ៍ឯកភាពម្ចាស់ការ ខ្លួនទីពឹងខ្លួន បក្សគ្រប់ថ្នាក់ត្រូវរៀបចំផែនការឲ្យបានល្អិត ដោយមានតួលេខច្បាស់លាស់ក្នុងគ្រប់វិស័យ តាំងពីភូមិភាគ តំបន់ ស្រុក រហូតដល់សហករណ៍។ ហើយត្រូវធ្វើការពន្យល់ណែនាំមហាជននៅក្នុងសហករណ៍។ ត្រូវតែខិតខំបំពាក់ទស្សនៈគោលជំហរវណ្ណៈអធនឲ្យកសិករ។ បើមិនដូច្នេះទេយើងមិនអាចកែប្រែកសិកម្មប្រទេសយើងឲ្យទៅជាកសិកម្មទំនើបបានទេ។ យើងធ្វើដូចដែលយើងធ្លាប់បានធ្វើកាលពីសម័យសង្គ្រាម គឺបំផុសចលនាមហាជនឲ្យមហាជនចូលរួមក្នុងចលនា។ កាលណាចលនាកម្រើកហើយ បញ្ហាទឹកដោះស្រាយបានពាក់កណ្ដាលហើយ។ យើងធ្វើដូច្នេះបានជោគជ័យកាលពីសង្គ្រាម។ ឥឡូវកាន់តែងាយស្រួលថែមទៀត។ បញ្ហានៅតែបក្សតាមថ្នាក់ផ្សេងៗ រៀបចំមាគ៌ាដឹកនាំរបស់ខ្លួនឲ្យបានត្រឹមត្រូវ និងកំណត់ទិសដៅសេដ្ឋកិច្ចរបស់ខ្លួនឲ្យបានច្បាស់លាស់។[២២០]

ត្រង់នេះ ខ្ញុំនឹកឃើញរឿងប្រមូលប្រជាជនទៅសង់ទំនប់ដីកប្រឡាយ។ គេវាយជង់ដាស់ប្រជាជនតាំងពីម៉ោង៣ ឬ៤ភ្លឺ។ ឯពីល្ងាចហូបបាយរួមដល់ម៉ោង១២យប់មិនទាន់ហើយផង ដោយខ្វះចាន ត្រូវដាក់វេនគ្នាដើម្បីចូលហូបបាយ។ ព្រឹកឡើងគេវាយជង់ដាស់ប្រជាជនតាំងពីម៉ោង៣ ឬ៤ភ្លឺដើម្បី

---

[២២០] សូមអានឧបសម្ព័ន្ធទី៤

តម្រង់ផ្លូវៗ ទម្រាំតម្រង់ផ្លូវហើយភ្លឺល្មមៗ ហើយគេប្រមូលប្រជាជនទៅការដ្ឋានដោយមិនគិតថា នៅទីនោះមានចបកាប់ប៉ុន្មាន បង្គីប៉ុន្មាន ដូច្នេះត្រូវយកប៉ុន្មាននាក់ទៅការដ្ឋានបានហើយ ទុកប៉ុន្មាននាក់ឲ្យគេធ្វើការអ្វីផ្សេង ឬឲ្យផ្លាស់វេនគ្នាសម្រាកនោះទេ។ រឿងនេះលេខាភូមិភាគ និងលេខាតំបន់អត់ចុះទៅតាមដានណែនាំទេ។ ចាំពួដល់ប៉ុលពតទើបប៉ុលពតណែនាំល្អិតក្នុងអង្គប្រជុំគណៈមជ្ឈិមៗ ឥឡូវនេះខ្ញុំនិកត្រឡប់ទៅក្រោយវិញ ទើបខ្ញុំឃើញថាការ "រៀបចំផែនការឲ្យបានល្អិត ដោយមានតួលេខច្បាស់លាស់ក្នុងគ្រប់វិស័យ តាំងពីភូមិភាគ តំបន់ ស្រុក រហូតដល់សហករណ៍" គ្មាននរណាធ្វើបានទេ សូម្បីតែលេខាភូមិភាគ លេខាតំបន់ក៏មិនចេះធ្វើដែរ។

ប៉ុន្តែតាមយោបល់ខ្ញុំ រឿងនេះមិនជារឿងបច្ចេកទេសទេ។ បញ្ហាសំខាន់គឺស្មារតីទទួលខុសត្រូវ យកចិត្តទុកដាក់ចំពោះវាសនាជាតិ វាសនាប្រជាជន ស្មារតីទទួលខុសត្រូវចំពោះជីវិតមនុស្ស។

នៅចុងបញ្ចប់នេះ តើយើងអាចសរុបបានយ៉ាងម៉េច អំពីរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកស្រាវជ្រាវភាគច្រើនយល់ឃើញថារបបនេះត្រូវរលំដួលដោយសារតែនយោបាយជ្រុលហួសរបស់ ប៉ុលពត នៅក្រោយឆ្នាំ១៩៧៥។

លោក ហ្វីលិព ហ្សុត គាត់បានគូសសង្កត់ធ្ងន់អំពីជាតុសត្តិភូមិរបស់ប្រធានភូមិភាគទាំង៦។ ហើយគាត់ថែមទាំងបញ្ជាក់ថា បញ្ហានេះមិនមែនជាការចែដន្យអ្វីទេ គឺគេទាំងឡាយបានចាប់ផ្តើមជីវិតតស៊ូរបស់គេ ក្រោមការដឹកនាំរបស់វៀតណាមៗ លោកបានឃើញថា វៀតណាមបានបង្កើតកងទ័ពខ្មែររំដោះសីហនុនិយមៗ តែលោកមិនបានឃើញថាវៀតណាម បានប្រើចាន់ចក្រីឱ្យក្លែងខ្លួនជាកងទ័ពរំដោះ ដើម្បីបោកប្រាស់សម្តេចនរោត្តមសីហនុ។ មិនបានឃើញវៀតណាមលូកដៃចូលមកកកូរផ្ទៃក្នុងបក្ស ប.ក.ក និង កងទ័ពតស៊ូកម្ពុជាបែកបាក់គ្នាយ៉ាងណាទេ។ គាត់ក៏មិនបានឃើញកំណាត់ហេតុដែលអង្គប្រជុំគណៈអចិន្ត្រៃយ៍បើកទូលាយរបស់ប.ក.ក ចុះថ្ងៃទី១៤ ឧសភា ឆ្នាំ១៩៧៦ដែរ។



តាមខ្ញុំយល់ ការដែលវៀតណាមលូកដៃចូលមកកកូរផ្ទៃក្នុង ប.ក.ក និងកម្លាំងតស៊ូកម្ពុជា និង ឱសានវាទរបស់វៀតណាមនាខែ ឧសភា ឆ្នាំ ១៩៧៦ មិនមែនជាព្រឹត្តិការណ៍ដាច់ដោយឡែកពីគ្នាទេ។ បញ្ហានេះហើយដែលត្រូវស្រាវជ្រាវថែមទៀត។

ការពិតការខិតខំរបស់ខ្ញុំ ដើម្បីពន្យល់រយៈកាលនេះនៃប្រវត្តិសាស្ត្រប្រទេសយើង គឺដើម្បីជម្រាប់អំពីអ្វីដែលខ្ញុំយល់ថា ជាការពិតនៃប្រវត្តិសាស្ត្រជាតិយើងតាមដែលខ្ញុំបាន "ស្រាវជ្រាវ" ដូចបានជម្រាប់មកហើយតែប៉ុណ្ណោះ។ ក្នុងន័យនេះខ្ញុំសង្ឃឹមថា ខ្ញុំបានរួមចំណែកដើម្បីជូនឯកសារខ្លះដែលអាចមានប្រយោជន៍ ដើម្បីបើកលទ្ធភាពធ្វើការស្រាវជ្រាវតទៅមុខទៀត តាមផ្លូវមួយ ដែលអាចសមស្របនិងប្រវត្តិសាស្ត្រជាតិយើង ជាងអ្វីដែលគេបាននិយាយរហូតមកដល់ពេលនេះ។ តែនៅមានការច្រើនណាស់ដែលត្រូវស្រាវជ្រាវថែមទៀត។ ខ្ញុំយល់ឃើញថា ចលនាកម្ពុជាប្រជាធិបតេយ្យបានដើរតួសំខាន់ក្នុងរយៈកាលមួយនៃប្រវត្តិសាស្ត្រជាតិទៅហើយ គ្មាននរណាអាចកោសលុបបានទេ។ បើមានអ្នកណាកោស ឬលុប ឬក្រឡែនោះនឹងនាំឲ្យគេឃើញស្នាមកោស ឬស្នាមលុបកែក្រឡែ។ ពីព្រោះអ្វី? ពីព្រោះរឿងវាច្បាស់ណាស់ថា សាឡុតស ឬប៉ុលពតបានបូជាអស់មួយជីវិតរបស់គាត់ ដើម្បីប្រយុទ្ធជាមួយអាមេរិកផង ពួកកុម្មុយនីស្តវៀតណាមផង ការពារអធិបតេយ្យរបស់ជាតិ។ ហើយគេម្នាក់ៗសុទ្ធតែមានស្មៀតមានឧបាយកល ដើម្បីអូសទាញ ឬបំភ័ន្តកម្លាំងជាតិ និងកម្លាំងផ្ទៃក្នុងឲ្យទៅជាមួយគេ។ ដូច្នេះការប្រយុទ្ធតឹងតែងណាស់ សង្អៀតណាស់ចំពោះប្រទេសយើង ដែលជាប្រទេសតូច។

កាលពីឆ្នាំ១៩៦០ ខ្ញុំក៏ដូច "បញ្ញាជនចំរើន" ផ្សេងទៀតលុះទៅសំណូមពរដ៏ជ្រាលជ្រៅចង់បានសេដ្ឋកិច្ចឯករាជ្យមួយ សម្រាប់ជាមូលដ្ឋាននៃឯករាជ្យភាពរបស់ប្រទេសខ្ញុំ និង ទៅដោយឆន្ទៈមួយដ៏រឹងមាំ ចង់បញ្ចប់បុព្វសិទ្ធ និងអំពើពុករលួយ ដែលវានាំឱ្យមនុស្សមួយក្តាប់តូចចេះតែមានឡើងៗ មិនចេះអៀន មិនចេះខ្មាស់ ទន្ទឹមនឹងទុក្ខសោកវេទនារហេមរហាម មិនចេះចប់ មិន

ចេះហើយរបស់មហាជនដ៏ច្រើនមហិមា ខ្ញុំបានខិតខំប្រយុទ្ធតាមមធ្យោបាយដែលខ្ញុំមានកាលពីខ្ញុំនៅធ្វើជាតំណាងរាស្ត្រ។ ប៉ុន្តែខ្ញុំត្រូវចាញ់ ហើយត្រូវបង្ខំចិត្តរត់ចេញពីភ្នំពេញដើម្បីសង្គ្រោះអាយុជីវិតរបស់ខ្ញុំ មកជ្រកកោនក្រោមកិច្ចការពារនៃចលនាមួយ ដែលតាមរយៈមនុស្សខ្លះដែលខ្ញុំធ្លាប់ស្គាល់នៅប៉ារីស កំពុងតែខិតខំតាមទិសដៅមួយប្រហាក់ប្រហែលខ្ញុំដែរ តែតាមវិធីមួយផ្សេងដែលខ្ញុំធ្វើមិនបាន។

ឥឡូវនេះទស្សនៈគោលជំហររបស់ខ្ញុំ ក៏នៅតែដដែលឥតមានអ្វីប្រែប្រួលទេ។

ប៉ុន្តែបើនិយាយពីមនោសញ្ចេតនាខ្ញុំផ្ទាល់វិញ ពីមុនខ្ញុំជឿថា កុម្មុយនីស្តជាផ្លូវតែមួយគត់ ដើម្បីប្រទេសយើងនឹងប្រជាជនយើងទទួលបានឯករាជ្យនិងអធិបតេយ្យ សេចក្តីថ្លៃថ្នូរ និង សុភមង្គលអីចឹងមែន។ ពីមុនខ្ញុំជឿថាកុម្មុយនីស្ត គឺភាតរៈភាពអន្តរជាតិបរិសុទ្ធ។ ប៉ុន្តែពិសោធន៍ជូរចត់ណាស់។ ការលាក់ពុត មហិច្ឆិតាលោភលន់ ឧបាយកលខ្មៅងងឹត ធ្មិនក្បាលស៊ីក្បាល ធ្មិនកន្ទុយស៊ីកន្ទុយ កម្លាំងបាយចង់ស៊ីខ្លួងលើប្រទេសយើងមានហូរហែជាប់មក។ តើខ្ញុំសោកស្តាយដោយសារជីវិតខ្ញុំឥតបានទទួលលទ្ធផលអ្វីសោះនោះទេ? អត់ទេ។ ក្នុងមួយជីវិតខ្ញុំនេះ ខ្ញុំបានខំអស់សមត្ថភាពរបស់ខ្ញុំ ធ្ងន់កាត់លំបាកវេទនា តាមលទ្ធភាពរបស់ខ្ញុំ ស្មោះត្រង់ចំពោះខ្លួនខ្ញុំជានិច្ច ចំពោះប្រទេសខ្ញុំ ចំពោះប្រជាជនខ្ញុំ ចំពោះជាតិខ្ញុំជានិច្ច។ ខ្ញុំមិនមានអ្វីនឹងខ្មាស់អៀននរណាទេ។

បើនិយាយពីមនោសញ្ចេតនាផ្ទាល់ខ្លួនវិញ អ្វីដែលខ្ញុំស្តាយជាងគេ គឺប្រទេសយើងបាត់បង់ឱកាសដើម្បីផ្សះផ្សាជាតិ តាមកិច្ចព្រមព្រៀងប៉ារីស។ ហេតុផលដូចខ្ញុំបាននិយាយក្នុងលំនាំដើមមកហើយ។ នៅក្នុងជំពូកទី៦តទៅនេះ យើងសាកល្បងពិនិត្យល្អិតថែមទៀតអំពីស្នៀតឧបាយកល ក្រលិចក្រឡុចយ៉ាងម៉េចខ្លះ ដើម្បីបង្វែរ ឬបំភ្លៃកិច្ចព្រមព្រៀងប៉ារីស កំចាត់ខ្មែរក្រហមមិនឲ្យមានការផ្សះផ្សាជាតិ៤ភាគី។